
យុន-ស្រ៊ុន
សំរស់ជីវិត
ឬ
សៀវភៅគំហើញ

# ជម្រាបអ្នកអាន

ដូចអ្នកឆ្លងវិជ្ជាខ្លះយល់ដែរ ពេលនេះមានប្រយោជន៍អីនឹងសរសេរក្នុងលោកមួយដ៏រងកម្មក្រឡិចក្រឡុក សខ្មៅស្រេចចិត្ត។ អ្វីៗសព្វយ៉ាងសុទ្ធតែមិនអាចទាយទុកបាន សូម្បីខ្លួនឯងក៏មិនអាចថាទុកបានដែរ។ តែខ្ញុំយល់ថាជាជាងនៅស្ងៀម បៀមកង្វល់ម្នាក់ឯង ហោចណាស់ក៏គួរផ្លៀតលាតត្រដាងឲ្យគេឃើញគំហើញខ្លួនខ្លះ ព្រោះការដែលអ្នកអានបានឃើញបន្តិចបន្តួចនេះ បើមិនអីក៏បានត្រឹមឃើញដែរ។

កាលខ្ញុំឃើញពិភពលោកអាក្រក់ណាស់ គឺពេញដោយមនុស្សខូច សត្វ សាហាវ និងវត្ថុគំរក់។ ដូចព្រាហ្មណ៍បូរាណយល់មែន មនុស្សគ្រប់គ្នាកំពុងរស់ក្នុងកលិយុគ គឺអាក្រក់បីភាគសល់ល្អតែមួយភាគ។ រឿងរ៉ាវស្អុគស្មាញល្វីងមុខ រកសុខមិនឃើញគ្រប់បែបយ៉ាងនេះ មានរោគមិនឆ្អែតជាមេធំ អ្នកក្រវាល់ពាន់លានអ្នកខ្វះបាយទឹក ខ្វះទីលំនៅ ខ្វះជំនាញអ្នកមានមាសប្រាក់វាលបាវត្តញថា ខ្លួនក្រណាស់ កង្វះខ្លះខ្ញុំពុំអាចដឹងបានអ្នកលោភខាងសាងផ្ដេសផ្ដាស់លោភមិន ស្កប់ ខ្លះងាប់ហើយនៅមិនឈប់។ ថាថយក្រោយក៏ថាបាន រឿងនេះនាំឲ្យខ្ញុំ កោតសរសើរសំណាងសត្វថាល្អប្រសើរ និង សុខជាងមនុស្សព្រោះសត្វរស់មួយឆ្អែត រកមួយឆ្អែតគឺបានឆ្អែតជាងមនុស្ស។

ក្រោយមកខ្ញុំឃើញជីវិតខ្លួនឯងមិនដឹងមានន័យជាស្អី គឺដេកដើរឈរអង្គុយសើច យំញញឹម ព្រួយ មាន ក្រ ឈឺ ជា ថ្លៃ ថោក ខ្ពស់ ទាប ល្អ អាក្រក់ ទាំងនេះមិនដឹងដើម្បីអី និងបានជាអី។ នេះតាំងពីខ្ញុំមិនទាន់ឮឈ្មោះអាល់ប៊ែរកាមិស ឬ ហ្សង់ប៉ូលសាក ម៉េ្លះ ទាំងពីរនាក់ជាទស្សនវិទូបារាំងដ៏ល្បីល្បាញខាងទស្សនៈ Absurde និង Existentialisme។

ឥឡូវខ្ញុំឃើញផ្សេងពីមុន។ មែន ការដែលយល់ថាអ្វីៗសុទ្ធតែអាក្រក់សុទ្ធតែមិនដឹងជាស្អីនោះ នាំឲ្យខ្ញុំអស់សង្ឃឹម និងឲ្យខ្ញុំដេកស្ងៀមយ៉ាងយូរដោយអត់កើនអ្វីសោះ។ ខ្ញុំក៏ភ្ញាក់ថា ក្នុងលោកនេះពិតជាមាន និង មិនខ្វះអ្វីដែលល្អ ៖ មនុស្សល្អ សត្វល្អ កន្លែងល្អ សិល្បៈល្អ សៀវភៅ

ល្អ ។ល។ ហើយជីវិតយើង ជាអ្វីម្យ៉ាងដែលមានតម្លៃ ៖ ហោចណាស់ក៏គេមិនចង់ងាប់ ឬគេទទួលថាជីវិតមនុស្សថ្លៃជាងសត្វដែរ។ ដូចនេះ មនុស្សគួររួមគ្នាខំតែងជីវិតឲ្យល្អគ្រប់គ្នាគេឡើង។ ជាតឹកតាង អ្នកវិទ្យាសាស្ត្រ អ្នកប្រាជ្ញ អ្នកសីលធម៌ ទស្សនវិទូ អ្នកនយោបាយ ។ល។ ច្រើនណាស់ ច្រើនមកហើយ ហើយនឹងច្រើនទៅទៀត បានខំស៊ូបំពេញការនេះ។ សេចក្តីថាខ្ញុំគួរលែងស្ងៀម ហើយខំធ្វើអ្វីមួយឲ្យកើនលក្ខណៈល្អខ្លះនិងគេ ដោយសង្ឃឹមនិងជឿជាក់ថាថ្ងៃណាមួយពិភពលោកនឹងល្អប្រសើរមិនខាន។ គឺក្នុងគំនិតនេះហើយដែលសៀវភៅតូចនេះត្រូវកកើតរូបរាង......។

សរសេរនៅឆ្នាំ ១៩៦៨-៦៩-៧០ សំនេរនេះបានត្រូវបោះជាបីភាគ នៅឆ្នាំ ១៩៧០ ដោយមានចំណងជើងថា គំហើញ (អត្ថបទកំណាព្យបានត្រូវដាក់រួចដកពីការប្រឡងប្រជែងអក្សរសាស្ត្ររង្វាន់ក្រមង៉ុយនៃសមាគមអ្នកនិពន្ធខ្មែរ)។ ការបោះសារថ្មីនេះ ខ្ញុំបានកែសំរួលបន្ថយ និង បន្ថែមសំនេរខ្លះ សំនេរខ្លះអានឡើងវិញ ខ្ញុំអៀន ហើយសំរេចដាក់ចំណងជើងថាសំរស់ជីវិត។ ខ្ញុំគិតថា បើមនុស្សខំបន្ថយអ្វីដែលស្អុយអាក្រក់បន្តិចម្តង ហើយបង្កើនអ្វីដែលល្អប្រសើរបន្តិចម្តង នោះពិភពយើងនិងកាន់តែស្រស់ញញឹមមិនចាញ់ឋានសួគ៌ពេកឡើយ នៅពេលមួយ.........។

ខ្ញុំសូមធ្វើក្តីគោរពស្រឡាញ់ និងអំណរគុណយ៉ាងស្មោះចំពោះលោកគ្រូ អ្នកគ្រូ ទាំងសង្ឃ ទាំងគ្រហស្ថ ដែលបានបង្ហាឲ្យខ្ញុំស្រឡាញ់មនុស្ស ស្រឡាញ់ខ្មែរ និងស្រឡាញ់សំនេរ... ជាអាទិ៍ភិក្ខុ ប៉ាងខាត់ អ្នកគ្រូ អ៊ុង សូផាន លោកគ្រូ អាំជូន គយ សារុន កេងវ៉ាន់សាក និង ឈូក ម៉ឺងម៉ៅ។

**ឃុន ស្រ៊ុន**

# ស្នេហ៍ដីអត់ទឹក

វិរជនខំច្បាំងការពារព្រំដែន ព្រោះស្រឡាញ់ទឹកដី ទាំងដីទាំងទឹក។ តែខ្ញុំ ខ្ញុំមិនស្រឡាញ់ទាំងទឹកទាំងដីទេ ៖ ខ្ញុំស្នេហ៍តែដីប៉ុណ្ណោះ។ ខ្ញុំមិនស្នេហ៍ទឹកទេ ពិសេសដីណាមានទឹកដក់ខ្ញុំមិនត្រូវការជាដាច់ខាត។

រាល់ថ្ងៃ បើខ្ញុំខំគន់មើលផ្លូវណាដក់ទឹក ផ្លូវណាមិនដក់ទឹក ដីណាដក់ទឹក ដីណាមិនដក់ទឹក ដីណាចំមុខ ដីណាមិនចំមុខ ដីណាជិតផ្សារ ជិតបេនឡាន ដីណាឆ្ងាយផ្សារ ឆ្ងាយបេនឡាន ដីណាដីឡូត៍ ដីណាដីល្វែង ដីណាកម្មសិទ្ធិ ដីណាមិនកម្មសិទ្ធិ ដីណាមានម្ចាស់ ដីណាគ្មានម្ចាស់ ។ល។ នោះគឺព្រោះខ្ញុំស្រឡាញ់ដីនេះឯង។

ដីដែលខ្ញុំស្រឡាញ់ជាងគេ គឺដីក្រុង ពិសេសដីក្រុងហើយនៅជាប់ផ្លូវកៅស៊ូទៀត៖ ដីស្រែ ដីជាប់ស្រយាល ដីព្រំដែន ទុកឲ្យវីរជនគេបេតីចុះព្រោះគេខំការពារ ។ អ្នកខ្លះពោលថា ស្នេហាដីម្លឹងៗ ជាតិក្រោយកើតជា ជន្លេន ឬ ដង្កូវ មិនខាន ៖ ឲ្យគេថាចុះ! ខ្ញុំស្រឡាញ់ដីណាស់......

★ ★ ★

# ចង្ក្រមហាង

ខ្ញុំចូលចិត្តចង់ជួប ហើយចង់នៅជិតអ្នកចេះ និង អ្នកជា។ ក្រៅពីនេះខ្ញុំចង់សប្បាយសំបើមណាស់ ៖ សប្បាយដេក សប្បាយដើរ សប្បាយផឹក សប្បាយស៊ី សប្បាយច្រៀង សប្បាយរាំ សប្បាយថា សប្បាយធ្វើ សប្បាយគិត សប្បាយសរសេរ......ព្រោះសប្បាយនាំឲ្យអាយុវែង។

តែខ្ញុំមិនចង់កោរគេទេ ហើយក៏មិនចង់ឲ្យគេកោរខ្ញុំដែរ ។ រាល់ថ្ងៃ បើខ្ញុំខំទប់ខ្លួន និងទប់ចិត្ត មិនឲ្យដើរលេងសើច ស៊ីចាយសប្បាយជ្រុល នោះមិនមែនមកពីខ្ញុំកំណាញ់ ឬរកបានតិចជា

ដាច់ខាត តែព្រោះខ្ញុំខំពួន ខំគេចពីក្រុមមនុស្សដែលចាំអង្វៀមខ្ញុំ ។ ខ្ញុំឃើញហាងទាំងឡាយ ហាងរបស់ ហាងមាសពេជ្រ ហាងកង់ម៉ូតូឡាន ហាងស៊ីធឹក ហាងច្រៀងរាំង ហាងថ្នាំ ហាងពេទ្យ ហាងទិញលក់ ហាងបញ្ជាំ ហាងជួសជុល ហាងតូចធំ ហាងចាស់ថ្មី ហាងក្នុងស្រុក ហាងក្រៅស្រុក ដូចជាបើកទ្វារយ៉ាងធំៗ ភ្នែកក្រឡោតៗ បញ្ចេញចង្កូមគួរឲ្យព្រឺចាំសម្លឹងខ្ញុំ ចាំត្របាក់ខ្ញុំ ចាំបឺតលុយពីហោប៉ៅខ្ញុំ។ ក្រៅពីហាងរដ្ឋ ខ្ញុំឃើញហាងទាំងនោះមានទឹកមុខញញឹមដូចព្រាយ។ ដំណាលគ្នានេះ ខ្ញុំនឹកឃើញសម្ដីម្ដាយខ្ញុំ ដែលប្រដៅខ្ញុំជារឿយៗកាលនៅរៀន ថាកុំឲ្យខ្ញុំទម្លាប់ចាយធំ។ កាលនោះខ្ញុំមិនចង់ស្ដាប់ពាក្យប្រៃនេះទេ ព្រោះខ្ញុំគិតថា គាត់បង្ខាំងមិនឲ្យខ្ញុំសប្បាយ។ ឥឡូវ ខ្ញុំយល់ច្បាស់ និង ផ្សេងទៅវិញគឺ គាត់ខំទូន្មានយ៉ាងនេះព្រោះខ្លាចគេកោរកូនកម្សត់។

★ ★ ★

# អ្នកប្រាជ្ញខ្មែរមួយ

មិនទាន់ឮមាន ហើយមិនអាចមានប្រហែលផង ក្នុងប្រវត្តិអ្នកប្រាជ្ញ...មនុស្សម្នាក់ កូនអ្នកខ្សត់ដូចធនញ្ជ័យ ចេះរើបំរះពីការជិះជាន់របស់សេដ្ឋីហ៊ានប្រឆាំងព្រះរាជា ហើយធំបំផុតបានខំការពារនិងលើកវណ្ណៈអ្នកស្រុកដោយស្មោះ។ ឈ្មោះដ៏ក្រអូបល្បីរបស់កំពូលអ្នកប្រាជ្ញនេះ មិនឮខ្ទរត្រឹមតែខ្មែរគ្រប់គ្នាទេ សូម្បីនាម៉ឺន និងស្ដេចក្រុងចិន ក៏ស្ងើចសរសើរនិងសារភាពថាមិនដល់ដែរ។ តើត្រូវកោតប៉ុនណា កាលបើដល់ពេលចេញដំណើរ ស្ដេចបញ្ជាឲ្យរកសេះភ្លាមៗ ក្មេងអាយុជាង ១០ឆ្នាំដូចធនញ្ជ័យ ចេះឆក់បានសេះកូនអុកក្ដាប់យ៉ាងតឹងរត់ទៅជាមួយគេ។ តើត្រូវកោតប៉ុនណា កាលបើគេគ្រប់គ្នាមុជទឹកមកសុទ្ធតែមានពងមាន់នៅដៃ ធនញ្ជ័យងើបឡើងក្រាបទូលដោយដោះសារយ៉ាងធូរថាខ្លួនគ្មានពងព្រោះជាមាន់ឈ្មោល។ តើត្រូវកោតប៉ុនណា ដែលធនញ្ជ័យហ៊ានទយគូថឲ្យព្រះរាជា ដោយគ្មានភ័យស្លុតបន្តិច។ រួចគួរសរសើរប៉ុនណាដែរ ដែលធនញ្ជ័យបានដោះប្រស្នាឲ្យស្រុកខ្មែរមិនធ្លាក់ជាចំណុះក្រុងចិនហើយបានចំណេញសំពៅ

ដល់ទៅប្រាំរយ........រួចអ្នកប្រាជ្ញដ៏សែនប្រជាប្រិយ ដ៏មានគុណនិងដ៏មិនចេះរករឿងគេមុននេះ បានអីជារង្វាន់? ពិតណាស់ ក្រៅពីគេបណ្ដេញមិនឲ្យនៅជិត ខ្លាចដល់ដណ្ដើមរាជ្យ ក្រៅពីគេចង់សម្លាប់ចោល ក្រៅពីរស់រងទុក្ខគ្មានស្រាក រង្វាន់ដ៏ធំគឺស្លាប់ទៅបាននាម៉ឺនទាំងឡាយនាំគ្នាចោមជុះអាចម៍ និង ជុះនោមដាក់ផ្នូរកម្សត់។

★ ★ ★

## ញញឹមចាយ័ន

អ្នកញញឹម...ត្រជាក់... ប្រកបដោយលក្ខណៈគួរឲ្យគេទូទៅចង់ចូលជិត។ អ្នកសុភាពស្ងប់ មិនសៀម ស្លូតទូលាយជ្រៅនិងនឹង។ អ្នកតែងព្យាយាមជញ្ជឹង ថ្លឹងនិងគិតដោះស្រាយរឿងរ៉ាវលំបាកវេទនាសព្វបែបយ៉ាងរបស់មនុស្ស។ អ្នកពិតជាមានមេត្តាធម៌និងមនុស្សធម៌ដល់កំពូល បើអត់អ្វីបាយ និងអំបិលបានដែរ ត្រង់ឲ្យធ្វើបាបគេគឺមិនធ្វើទេ។

អ្នកលាចាកភពលោកយូរណាស់ហើយ តែឃើញនៅរបស់ជានិច្ច ។ ខ្ញុំស្រឡាញ់អ្នកណាស់...ហើយជនណាមានត្រចៀក ច្រមុះ មាត់ ថ្ងាស ចិញ្ចើម និងភ្នែកដូចអ្នក ជននោះខ្ញុំស្រឡាញ់រហូតខ្ញុំស្លាប់ ព្រោះបើមិនដល់ថ្នាក់ ជាម្លប់ដ៏ត្រជាក់ដូចអ្នក ហោចណាស់ក៏ជននោះខំលះបង់ការធ្វើបាបគេសព្វបែបយ៉ាងហើយខំសាងសុខឲ្យអ្នកជងទាំងពួងបន្តិចបន្តួចដែរ។

អ្នកមិនជាប់ជំពាក់និងមាសពេជ្រកែវកងស្រីស្នំឆ្វេងស្ដាំ វិមានល្វឹងល្វើយ សេនាហែហម ឬពាក្យលើកតំកើងហួសពិតជាដាច់ខាត...បើលោភក៏មិនលន់ដែរ គឺគ្រាន់តែជក់ចិត្តក្នុងការចង់ឲ្យគេគ្រប់គ្នាបានសុខ បានជា បានបាយបានផ្ទះនៅបានពេទ្យថៃ បានជួបជុំក្រុមញាតិ និងឃ្លាតសង្គ្រាម ឃ្លាតការទាត់ធាក់កាប់ចាក់ហូរឈាម ស្លាប់មនុស្សអាយុប៉ុននោះ។

ជីវិតអ្នកមានប្រយោជន៍ណាស់ចំពោះផែនដី ហើយពេលនេះទៀត បើមិនបានអ្វីក៏បានត្រឹមខ្ញុំនិងគេឯទៀតខ្លះ ស្រឡាញ់អ្នកយ៉ាងស្មោះ នឹកអ្នកយ៉ាងស្មោះ និងដកចិត្តពីអ្នកពុំរួចនោះ

ដែរ។ អ្នកអស់គ្រឿងសៅហ្មងពីក្នុងខ្លួនហើយ...អ្នកឈ្នះខ្លួនឯងហើយ...អ្នកជ្រះនិងថ្លាដូចទឹកជ្រោះ ក្នុងពិភពលោកនេះ ពេលនេះមានគេថាអ្នកអាក្រក់កើតទេ មានជាងណាចេះតែងថ្មឲ្យល្អមុខដូចនេះទេ...ហើយពេលណាទើបធម្មជាតិផ្ដល់លក្ខណៈឥតខ្ចោះ ឥតខ្ចកទាំងអស់នេះ ឲ្យមនុស្សទូទៅ?។

★ ★ ★

# ពូជស៊ីកេរ្តិ៍

ខ្ញុំជាមនុស្ស ជាខ្មែរ ជាមនុស្សផង ខ្មែរផង ឬមួយជាអ្វី?

ខ្ញុំកើតនៅស្រុកខ្មែរ មានសញ្ជាតិខ្មែរ តែមិនដឹងឈាមជ័រប្រាកដ ព្រោះមិនដឹងដូនតាខ្ញុំមានកំណើតពីតំបន់ណា ៖ បើគាត់មកពីព្រំខាងជើង ខ្ញុំត្រូវកាត់លាវ បើពីខាងលិច ត្រូវកាត់សៀម បើពីខាងត្បូងនិងខាងកើតត្រូវកាត់យួន បើនៅភ្នំពេញ ត្រូវកាត់ចិនឬចាមជ្វាឬអឺរុប ៖ បើមិនកាត់ឈាមក៏កាត់ផ្នត់គំនិតសម្ដីសម្ដែង និង របៀបរស់នៅដែរ ឬក៏បន្តិចបន្តួចដែរ។ ដូចនេះខ្ញុំប្រហែលមិនសុទ្ធជាខ្មែរពូជអង្គរដូចអ្នកផងទេ... ប៉ុន្តែខ្ញុំដឹងថាមានសិទ្ធិស៊ីកេរ្តិ៍ពីពូជអង្គរ... មានអង្គរជាដើម ៖ នៅមានសម្បត្តិល្អៗច្រើនទៀតដែលដូនតាខ្ញុំ បានកនិងសាងទុកជាកេរ្តិ៍ឲ្យខ្ញុំ និងឲ្យជនដែលមានសញ្ជាតិដូចខ្ញុំ។

ខ្ញុំពេញជាមនុស្សមែនឬទេ? ពិបាកថាដែរ។ តែមើលៗទៅខ្ញុំដូចជាមិនទាន់ពេញលក្ខណៈទេ ព្រោះគ្មានបានធ្វើអ្វីដុំកំភួនជាកេរ្តិ៍ឲ្យគេជាន់ក្រោយសោះ... មួយថ្ងៃៗឃើញតែស៊ីកេរ្តិ៍ មនុស្សមុនៗ ។ គេរស់ដូចខ្ញុំដែរ ខួរគេប៉ុនខ្ញុំដែរ តែគេបានរាវ និង រកឃើញអ្វីៗ ល្អៗ ថ្លៃៗ និងប្រណិតៗ ច្រើនណាស់ទុកឲ្យខ្ញុំ... នឹកៗទៅគួរអៀនខ្លួន៖ ថាគេស្បែកសចុះគ្រែងប្រាជ្ញាជាងខ្ញុំ ... ចុះអ្នកស្បែកលឿង និង ស្បែកខ្មៅ? តាមពិតមិនមែនមកពីស្បែកទេ តែមកពីគេមានចិត្តគំនិតចង់សាងកេរ្តិ៍ទុកឲ្យខ្ញុំស៊ីតែម្ដង... ។ វត្ថុសិល្បៈល្អៗ សៀវភៅល្អៗ ចំណេះរាក់ជ្រៅទ្រឹស្ដីផ្សេងៗ របស់របរផ្សេងៗ... ច្រើនណាស់ៗ ស៊ីមិនអស់ទេ... ស៊ីមួយជីវិត... ស៊ីតកូនចៅ...

ហើយដែលគួរអៀនខ្លាំងទៅទៀតនោះគឺជួនកាល ខ្ញុំទាស់នឹងអ្នកទាំងពួងរហូតប្តឹងផ្តល់កាប់សម្លាប់គ្នា ព្រោះរឿងស៊ីកេរ្តិ៍គេនេះឯង... (នេះមិនគិតពីកេរ្តិ៍ខ្លះ ដែលខ្ញុំទំពារមិនម៉ត់នោះផង...)។

★ ★ ★

## ភពខ្សត់មនុស្ស

មនុស្សស្លាប់ លែងជាមនុស្សហើយ។ មានប្រយោជន៍អី នឹងខំនឹកគិតអាណិត ទួញសោក បោកខ្លួនប្រាណរហូតស្គមស្គាំងរីងរៃ ព្រោះទួញរីងសមុទ្រ ក៏មិនអាចរស់ឡើងវិញដដែល។ ក្រៅពីស្តាយដោយខំកាត់ចិត្ត តើបានផលអី នឹងខំឲ្យទុក្ខ ៖ អ្នកស្លាប់លែងជាមនុស្សហើយ ហើយបើនៅ ក៏នៅត្រឹមជាមនុស្សដែលជាមនុស្សប៉ុណ្ណោះ សំនួរធំគឺសមល្មមនឹងស្លាប់ឬទេ បើមិនសមទើបត្រូវស្តាយ...។

មនុស្សច្រើនណាស់នៅរស់ តែមិនមែនឬមិនពេញជាមនុស្ស។ ក្មេងនិងជំទង់មិនទាន់ពេញជាមនុស្សទេ។ អ្នកដែលតាំងខ្លួនជាកំពូលគេក៏មិនមែនមនុស្សដែរ ៖ ទស្សនៈវិទូតែងពោលថា (ដើម្បីទៅជាមនុស្សត្រូវបដិសេធកុំឲ្យទៅជាអាទិទេព) ។ ជនណារមិលគុណ គេហៅក្រពើ អ្នកកាចឃោរឃៅ គេហៅខ្លា... អ្នកលាក់ពុតជាកញ្ជ្រោង... អ្នកធ្វើបាបគេដោយមិនចេញមុខ ជាឆ្មាលាក់ក្រចក... ហើយអ្នកផ្អែមសំបកក្រៅ គេហៅថាល្ងា។ បើខ្វះគំនិតបញ្ញា ខ្វះធម៌ប្រសើរខ្ពង់ខ្ពស់ នោះមានឈ្មោះថាសត្វ... តែមួយម៉ាត់គ្រប់។ យ៉ាងនេះទើបពេលមនុស្សខ្លះទាស់ទែងកាប់ចាក់ទាត់ធាក់បាញ់សម្លាប់គ្នា គេតែងពោលថា ខាំគ្នាដូចឆ្កែ ឬហែកហួរគ្នាដូចឆ្កែឆ្មា។ យ៉ាងនេះ ទើបគេតែងឮពាក្យ (ចោកឬស្អុយជាងអាចម៍ទៅទៀត) ពាក្យ (ក្រពើវង្វេងបឹង) ពាក្យ (ត្រីឆ្តោស៊ីកូនឯង) ពាក្យ (យក្ខិនី-ក្ងោកមាស-ខាំគ្នារឿញី-ស្វា-វៃក) ល និង ល ប្រើពាស

ពេញពិភពមនុស្ស។

ពេលនេះដីមានមនុស្សជាងបីពាន់លាននាក់ ហើយម្ភៃសាមសិបឆ្នាំទៀតនឹងឡើងដល់ប្រាំពីរពាន់លាននាក់។ ច្រើនដែរ... តែ តើមានមនុស្សពេញលេញមែនទែនប៉ុន្មាន? នឹងឆ្លើយឬរាប់ដឹងបាន លុះណាសង្គមមនុស្សរៀបចំបានត្រឹមត្រូវ។ គេអាចត្រឹមស្មង់ថា មិនច្រើនទេ ហើយបើគ្មានការអប់រំច្បាស់លាស់នោះនឹងថយទៅៗ តាមទំនោរនិងទំនាញធម្មជាតិដែលចេះតែចង់ទាញមនុស្សឲ្យលែងជាមនុស្ស។

★ ★ ★

## ចាញ់បោកសម្លាញ់

យើងធ្លាប់បង្រៀនទី២ ទី១ ឬទីបញ្ចប់ ម្នាក់ៗពីរបីឆ្នាំមកហើយ។ យើងធ្លាប់ស្គាល់ចិត្តគំនិតសិស្សខ្មែរខ្លះដែរហើយ។ ឆ្នាំនេះ ឆ្នាំទីបីនៃការរៀនច្បាប់នៅសាលាគរុវិជ្ជាជាន់ខ្ពស់នេះ មុននឹងចេញទៅធ្វើការ គេតម្រូវយើងរៀនចិត្តសាស្រ្ត គរុកោសល្យ មួយអាទិត្យបួនម៉ោង ពីសាស្រ្តចារ្យបារាំងម្នាក់... រៀនចិត្តសាស្រ្តកូនខ្មែរ ពីសាស្រ្តាចារ្យបារាំងម្នាក់។ ដំបូងយើងធុញដែរ តែយូរទៅមានអី សប្បាយដែរ ឬថាទំនេរដែរក៏ថាបាន ៖ មួយម៉ោងៗ យើងអង្គុយលេងតាមចិត្ត។ បូកទូរទាត់ដើមឆ្នាំ ដល់ចុងឆ្នាំ យើងរៀនបានស្គាល់បន្តិចបន្តួចពីសូក្រាត។ ប៉ុនណឹងហើយ មិត្តខ្លះ ដល់ម៉ោង ចិត្តសាស្រ្ត សំបុត្រ ពេទ្យបញ្ជាក់ថា ឈឺជានិច្ច។ ខ្ញុំស័យបន្តិចព្រោះធ្វើសិស្សច្បង តែមានអីយូរៗឈឺដូចតែគ្នា។

រឿងដែលខ្ញុំនឹកឃើញជានិច្ចនោះរឿងផ្សេង...

កាលនោះ មុនចូលឆ្នាំខ្មែរ នៅដំណាច់ខែមិនា សាស្រ្តាចារ្យបានដាក់កិច្ចការមួយឲ្យធ្វើយកពិន្ទុ។ កិច្ចការនេះត្រូវប្រមូលយកទៅកែនៅពេលចូលឆ្នាំរួច។ ប្រហែលដោយកិច្ចការនេះមិនសូវបានការ ឬដោយយើងមិននសូវស្នេហ៍ពិន្ទុ ឬក៏ដោយយើងអាចចម្លងគ្នាបានផង ព្រោះយើងតែងរៀនចូលគ្នាជាក្រុមៗ យើងសន្យាគ្នាថាអត់ធ្វើ។ ដល់ចូលកងតូចវិញ ប្រហែលដោយ

សាស្ត្រចារ្យឆរថា អ្នកណាមិនធ្វើ ត្រូវបានសូន្យមិនដឹង មិត្តភាគច្រើននាំគ្នាយកដាក់រពុយ។ ខ្ញុំមិនមានដឹងទេព្រោះខ្ញុំឈប់ទៅរៀន តែបើដឹងខ្ញុំមិនធ្វើដែរ។ ទីបំផុតខ្ញុំបានសូន្យ សូន្យនេះនេះនាំឲ្យខ្ញុំត្រូវទទួកាចាត់ថ្នាកលប់ តោងកន្ទុយគេ។ ពេលរើសកន្លែងធ្វើការ ខ្ញុំត្រូវរើសក្រោយគេ។ ខ្ញុំនឹកស្ដាយយ៉ាងខ្លាំង មិនមែនស្ដាយរឿងកន្លែងទេ តែស្ដាយត្រង់រៀនបានប៉ុននេះដែរ មិនគួរចាញ់បោកមិត្តយ៉ាងនេះសោះ...។

★ ★ ★

# ស្រឡាញ់ល្បែងអុក

អុក (ចត្រង្គ) កើតដំបូងនៅប្រទេសឥណ្ឌា ដោយសារព្រាហ្មណ៍ម្នាក់ជារាជគ្រូនៃបុត្រក្សត្រមួយអង្គ ចង់ទូន្មានបង្ហាញបុត្រក្សត្រនោះថាស្ដេចមិនអាចធ្វើអីកើតទេ បើគ្មានសេនា។ យុវក្សត្រពេញព្រះទ័យណាស់ ទ្រង់ប្រទានរង្វាន់មួយឲ្យព្រាហ្មណ៍ជ្រើសយក។ ព្រាហ្មណ៍សុំយកចំនួនគ្រាប់ស្រូវសាលីឲ្យបានដូចតទៅ គឺសុំឲ្យបានចំនួនគ្រាន់នៅគ្រប់ហុកសិបបួនក្រឡា ដោយក្រឡាទី១ មាន១គ្រាប់ ក្រឡាទី២ មាន២គ្រាប់ ក្រឡាទី៣ មាន៣គ្រាប់ ក្រឡាទី៤មាន៤គ្រាប់ ក្រឡាទី៥ មាន១៦គ្រាប់... សេចក្ដីថា ចំនួនគ្រាប់ពីក្រឡាមួយទៅក្រឡាមួយទៀត ត្រូវគុណនឹងពិរជានិច្ច... ស្ដេចយល់ព្រមព្រោះនឹកថាមិនច្រើនទេ។ តែដល់ពេលប្រទានស្ដេចរកគ្រាប់ស្រូវមិនបានគ្រប់សោះ ទោះកើបពីប្រទេសឥណ្ឌាទាំងមូលមកប្រទានក៏មិនគ្រប់ដែរ។ តាមលេខចំនួនដែលព្រាហ្មណ៍សុំមាន ១៨ ៤៤៦ ៧៤៤ ៧០៩ ៥៥១ ៦១៥គ្រាប់។ ដើម្បីឲ្យបានចំនួននេះគេត្រូវដាំស្រូវពេញផ្ទៃដែនទាំងមូលចំនួន ៧៩ដង... ល្បែងនេះត្រូវប្រជាជនឥណ្ឌាស្គាល់ទូទៅនៅរវាងឆ្នាំ ៥០០ នៃគ.ស ហើយត្រូវពួកអឺរ៉ុបស្គាល់នៅសតវត្សទី៩...។

តាមថ្លឹងព្រាហ្មណ៍ដែលបង្កើតល្បែងដ៏ប្រើល្បិច ដ៏ល្អលេងឥតខ្វោះនេះប្រាជ្ញាលោកមិនចាញស្មេររឿងមហោសថជាតកទេ។ បើលោករស់ ហើយបើខ្ញុំអាច ខ្ញុំនឹងជូនងារលោកភ្លាមថាជាកំពូលបណ្ឌិត ឬ កំពូលអ្នកប្រាជ្ញា។

បើគេកុំសង្វាតភ្នាល់ ដូចហាងកាត់សក់ខ្លះ កន្លែងខ្លះ ឬ អ្នកលេងខ្លះនោះល្បែងអុកសប្បាយជាងបៀទៅទៀត។ គេចាក់ត្រី ចុះនាង ចុះគោល ចុះសេះ កាត់គ្នាព្រួសព្រះ អុកគ្នាផុងផាំង អង្គុគ្នាចុះឡើងបញ្ឆោតគ្នាចុះឡើង មួយសន្ទុះឈ្នះចាញ់គ្នា ឬ ស្មើគ្នា...ហ៊ោគឺល។

លេងយូរឡើង ខ្ញុំគិតឡើងមើលគេលេងយូរឡើងខ្ញុំគិតឡើង...... តែគិតយូរៗទៅ ក្រៅពីសប្បាយ ខ្ញុំទៅជាអាណិត... មិនមែនអាណិតអ្នកលេងខ្លះដែលឈ្នះចាញ់ម្តងៗ វាលរយពាន់នោះទេ គេមានលុយទើបគេលេង តែអាណិតកូនទាំងឡាយដែលត្រូវគេឲ្យស៊ីគ្នា ឬ ដូរគ្នាជាល្បែង ឬជាប្រដាប់ សម្រាប់គេ ឈ្នះចាញ់សើរហ៊ោទៅវិញ។ តើគេសប្បាយដោយឃើញកូនទាំងនោះប្រយុទ្ធគ្នាឬ? គេយកកូនទាំងនោះឲ្យប្រយុទ្ធគ្នា ដើម្បីគេសប្បាយឬ? ឱ! ល្បែងអុកដ៏សប្បាយ... ត្រីទាំងអស់១៦ (កូនទាំងអស់៣២) ប្រយុទ្ធគ្នាយ៉ាងល្អមើលលើក្រឡា ៦៤។ ត្រីទាំងឡាយកិលទៅមុខទាំងសងខាងរហូតទល់គ្នាជាប់ ដោយមិនអាចថយក្រោយបាន វៀរលែងតែពេលណាបានឡើងសក្តិជាត្រីបក។ បើគេដូចជាគិតសម្មើមណាស់ទំរាំកាត់សេះកាត់ទូកមួយៗ ឬក៏ទំរាំលួចសេះលួសទូកមួយៗ នោះដល់គេកាក់ត្រី ឬ ដូរត្រីឬលួសត្រីមួយពីរវិញវាជារឿងងាយធម្មតានិងផុយល្អក។ ប្រយុទ្ធម្តងៗទំរាំឈ្នះចាញ់ ទូកអាចសល់ទាំងពីរចំណែកត្រីបូកទាំងសងខាង ជូននៅមិនដល់បួនប្រាំផង ដើម្បីខុនមួយ ត្រីត្រូវស៊ីគ្នាលេងអស់ចំនួនបីភាគបួនយ៉ាងតិច។

★ ★ ★

## ឆ្អែតភ្លាមទៅ

ឆ្អែតភ្លាមទៅ! ផ្លូវមានតែមួយនេះឯង។ ដើម្បីកុំឲ្យក្លាយជាកញ្ចះពេលវេលាដែលចាំតែទំពាអ្នកឲ្យធ្លាក់ទៅបាតដី ចូរអ្នកឆ្អែតឲ្យហើយទៅ។ ស្រីស្រាបៀបាបបុណ្យ ល្ខោនកុន ចំណង់ជំនក់ លុយ ឡាន អ្វីក៏បានដែរឲ្យតែឆ្អែតឲ្យហើយ។ មានអ្វីត្រូវគិត មានអ្វីត្រូវខ្វល់ មានអ្វីត្រូវព្រួយ? ធ្វើយ៉ាងណាឲ្យតែបានឆ្អែតគ្រប់គ្នា។ ធម្មជាតិ ចែកដៃពីរ កម្លាំងបាយ និងខួរក្បាលឲ្យ

យើងគ្រប់គ្នាដើម្បីជូរយកឆ្អែតនេះឯង ពិសេសឆ្អែតបាយ ឆ្អែតលំនៅ ឆ្អែតជនា និងកិច្ចធានាពេលខ្លួនចាស់។ មុននឹងស្ទុះស្ទារ រត់ប្រជែងគ្នាទៅមុខទៀត គួរឆ្អែតអ្វីដែលត្រូវឆ្អែតឲ្យបានគ្រប់គ្នាសិនព្រោះយើងទាំងអស់គ្នាជាមនុស្ស។

ពេលណាក៏ដូចពេលណាដែរ នៅម្នាក់ឯងក្តី ជុំគ្នាក្តី កំពុងកំសាន្តក្តីកំពុងវេទនាក្តី កាលណាអ្នកនឹកឃ្លាន ចូរសួរភ្លាម ទៅមេឃ ទៅដី ទៅព្រៃភ្នំ ទៅបក្សា ទៅនាទ្បិកា ទៅអ្នកជា អ្នកជាប់ទ្រុង អ្នកករី អ្នកកាត់ក្តី អ្នកចំរៀង អ្នកជប់លៀង អ្នកក្ជួររាស់ អ្នកលីសែង -ល- ថាតើថ្មើម៉ាណទៅហើយ។ មេឃដី ព្រៃភ្នំ នាទ្បិក បក្សា អ្នកជា អ្នកជាប់ទ្រុង អ្នកកំណាព្យ អ្នកចំរៀង អ្នកជប់លៀងនឹងឆ្លើយតបវិញយ៉ាងរហ័សថា ដល់ពេលដែលត្រូវឆ្អែតគ្រប់គ្នាហើយ ហើយពាក្យដែលល្អពីរោះ និង ខ្ពង់ខ្ពស់ជាងគេក្នុងវចនានុក្រមខ្មែរប្រហែលពាក្យឆ្អែត... ឆ្អែតគ្រប់គ្នា... នេះឯង។

★ ★ ★

## ជនដែលខ្ញុំអាណិត

លោកនេះ ពេលនេះ មនុស្សច្រើនណាស់បាន (ខំ) គ្រប់យ៉ាងព្រោះចង់បាត់អផ្សុក ចង់ស្រណុក ចង់សប្បាយ សប្បាយតាំងពីម៉ែឪ រហូតតកូនចៅ... មួយថ្ងៃៗគ្មានធ្វើអ្វីស្រក់ញើសទេ ឃើញតែតែងកាយឆើតឆាយ ដេកដើរ រាំច្រៀង ស៊ីផឹកនាយអាយ ចាយលេងយ៉ាងធូរ អាងរកបានធូរ។ យូរៗទៅពេករាល់ថ្ងៃទៅ លែងសប្បាយ នៅតែអផ្សុក រឹតតែអផ្សុក នៅតែអផ្សុក នៅតែឈឺ ឈឺនឹងអផ្សុកលើសគេឯងផង។

ជីវិតយ៉ាងនេះ ខ្ញុំឃើញ ខ្ញុំអាណិតជួសះ គេខូចឈ្មោះ គេរកសុខមិនបាន ដោយចៀសឈឺ ឬអផ្សុកមិនផុត ហើយខ្លួនគេដូចជាមានកម្ម គឺខំខាតឈ្មោះនេះ ដើម្បីកូនចៅ ជាក្មេងសំណាងទៅវិញ ៖ អ្នកអត់កូនរឹតតែកើតទុក្ខ... រឿងចាស់ទៅគ្មាននរណាថែ ជាទុក្ខតូចទេ ទុក្ខធំគឺភ័យពេលខ្លួនស្លាប់មិនដឹងចែកកំណប់ឲ្យអ្នកដទៃណា។ ធម្មតា គេទេដែលត្រូវអាណិតខ្ញុំ តែខ្ញុំ

អាណិតគេយ៉ាងស្មោះ និង យ៉ាងពិត។

★ ★ ★

## ស្រីដែលខ្ញុំស្រឡាញ់

ស្រីដែលខ្ញុំស្រឡាញ់មានរាងមិនជាត់ពេក មិនស្គមពេកមិនទាបពេក មិនខ្ពស់ពេក មានសម្ដីមិនគ្រលពេក មិនគ្រលួចពេកមិនប្រៃដូចទឹកសមុទ្រពេក និងមិនផ្អែមដូចទឹកត្នោតពេក។ នាងមិនចេះហ៊ឺហា ហេកហាក ឆើតឆាយពេក និងមិនឈ្លក់ទឹកម៉ាស៊ីនពេក។ នាងមានទឹកមុខញញឹម... ញញឹមជានិច្ចទោះមួយម៉ាត់ក៏ញញឹមដែរ តែកុំញញឹមដាច់បង្កៀរពេកដែរ។ ចិត្តនាងធូន់ធូន់ជានិច្ច តែក៏មិនធូន់ពេកដល់ថ្នាក់សើចដាក់អ្នករំលោភបំពាននោះដែរ។ នាងសុភាព ទាំងជិតទាំងឆ្ងាយ នាងទូលាយ រួចនាងស្មោះ... ស្មោះនឹងខ្ញុំ ស្មោះនឹងបងប្អូនខ្ញុំ ទាំងជិតទាំងឆ្ងាយ ស្មោះនឹងម៉ែឪខ្ញុំ ពិសេសស្មោះនឹងមនុស្សទូទៅ។ នាងចេះរៀបចំចាត់ចែង ផ្ទះសំបែង ដូចគេទាំងពួងដែរ តែនាងចេះស្លរឲ្យឆ្ងាយ់ដោយអស់ប្រាក់តិច ហើយធំបំផុត គឺនាងចេះមើលថៃ និងណែនាំកូនចៅ។ បើនាងចូលចិត្តអាននិងគិតផង នោះរឹតតែប្រសើរទៅទៀត។

និយាយឲ្យខ្លី ស្រីដែលខ្ញុំស្រឡាញ់ ជានារីមិនពេក ៖ រាងក៏មិនពេក ឫកក៏មិនពេក បើនឹងថា ងាយរកក៏មិនងាយពេក តែបើនឹងថាពិបាករកវិញក៏ដូចជាមិនពិបាកពេក។

★ ★ ★

## ស្រឡាញ់ទស្សនវិទូ

ទស្សនវិទូជាអ្នកខំគិតរកសុខ ឲ្យគេឯងតាមចំណេះផង តាមសីលធម៌ផង។ អ្នកចេះទាំងឡាយ អ្នកគណិតក្ដី អ្នករូបសាស្ត្រគីមីក្ដី តារាវិទូក្ដី ធម្មជាតិវិទូក្ដី... ម្នាក់ៗ នឹងទៅជាទស្សនវិទូកាលណាមានគោលគំនិតមួយជាក់ គឺរកសុខឲ្យគេឯង។ គោលនេះនាំឲ្យទស្សនវិទូមានការ

ប្រកាន់ ឬ គោលជំហរច្បាស់លាស់មួយជីវិត។

ព្រះពុទ្ធ ជាទស្សនវិទូមួយ។ គំហើញលោក គឺធម៌ ៨៦ ០០០ ធម្មក្ខណ្ឌដែលចែងពីទុក្ខក្នុងជីវិត។ល។ ឯគោលគំនិតលោកវិញ គឺខំរកសុខឲ្យមនុស្សទូទៅ។ លោកលះបង់គ្រួសារលោកទ្រាំពិបាកខ្លួនឯង ដើម្បីការពារអ្វីដែលលោកយល់ថា ត្រូវ ល្អ និងនាំឲ្យសុខ។

គំនិតរកសុខឲ្យគេ នាំឲ្យទស្សនវិទូភាគច្រើន ហ៊ានពុះពារ ឬ រងទុក្ខទោសសព្វយ៉ាង។ ទស្សនវិទូក្រិចឈ្មោះសូក្រាត បានសុខចិត្តទទួលទោសផឹកថ្នាំពុលឲ្យស្លាប់ ដោយមិនព្រមរត់គេចខ្លួន ដើម្បីយកឈ្នះគំនិតក្លែងក្លាយរបស់អ្នកគ្រប់គ្រងនឹងច្បាប់គ្រប់គ្រងជំនាន់នោះ។ លោក ឌីដឺរ៉ូ វ៉ុលទែរ ហ្សង់ប៉ូលសាក កាមិល និងទស្សនវិទូច្រើនទៀត សុទ្ធតែធ្លាប់ជាប់គុកព្រោះរឿងការពារសិទ្ធ សេរីភាព និងយុត្តិធម៌ក្នុងសង្គមមនុស្ស។ ធម្មតាទេ ដែលទស្សនវិទូគិតយល់ឬប្រកាន់ មិនដូចគ្នាគឺខ្លះថាអញ្ចេះល្អ ខ្លះថាអញ្ចុះល្អ ហើយខំការពារ គោលគំនិតរៀងៗខ្លួននោះ ត្រង់នេះក៏ទស្សនវិទូម្នាក់អាងលើការពិត ការពន្យល់រកហេតុផល ការដោះស្រាយបំភ្លឺគេឯង ដោយមិនបង្ខំគេឲ្យជឿ ឬធ្វើតាមខ្លួននោះដែរ ពិសេសទស្សនវិទូមិនដែលយកគេឯងឲ្យបម្រើ ការទាស់គ្នារបស់ខ្លួនជាដាច់ខាត។ សេចក្តីនេះនាំឲ្យខ្ញុំស្រឡាញ់ទស្សនវិទូ។ នៅមានលក្ខណៈល្អៗច្រើនទៀតនាំឲ្យខ្ញុំកោតនឹងសរសើរលោក។ ក្រៅពីមិនចេះបង្ខំគេឯង ក្រៅពីមិនចេះអួតអាងដាក់គេឯង។ ឧ- សូក្រាតនិយាយថា ខ្ញុំចេះពាក្យតែមួយម៉ាត់ពាក្យនេះ គឺខ្ញុំអត់ចេះអ្វីសោះ។ ទស្សនវិទូថែមទាំងជាអ្នកដែលមិនហ៊ានសម្លាប់គេ នឹងមិនសម្លាប់គេតែម្តង។ បើលោកគិតខំដោះបញ្ហាសព្វយ៉ាងមួយជីវិតនោះ គឺដើម្បីជួយគេដោយស្មោះ ដោយគ្មានក្រវិកក្រវក់នឹងគ្មានលាក់គំនួច ហើយបើលោកក្លាយជាមនុស្សឆ្កួត ក៏ឆ្កួតត្រឹមខំរកសុខមែនទែនឲ្យគេប៉ុណ្ណោះ។

★ ★ ★

## ធ្វើទស្សនវិជ្ជា គឺរៀនខាប់

ដូចសូក្រាតនិយាយមែន យើងមិនអាចស្គាល់ងាប់ឲ្យពិត ឬច្បាស់ឡើយ ព្រោះបើយើង

នៅទីណា ទីនោះគ្មានទេ ហើយបើវាមកដល់វិញនោះលែងមានយើង។ តែដែលយើងអាចដឹងជាក់ គឺមនុស្សគ្រប់គ្នាខ្លាចងាប់។ មនុស្សខ្លាចងាប់តាំងពីអាយុប្រហែល ១៥ឆ្នាំម្ល៉េះ។ ភស្តុតាងមានច្រើន ៖ ខ្លះពេលឈឺធ្ងន់ ស៊ូលក់គោ ក្របី ស្រែចំការ ទៅជារបហាម សុំកុំឲ្យតែងាប់ ខ្លះធ្វើបាបគេឯងសព្វយ៉ាង ដើម្បីឲ្យខ្លួនរស់ ខ្លះអាក្រក់ហើយសុំកុំឲ្យគេនិយាយពីខ្លួនព្រោះខ្លាចជាប់ទោស។ ក្នុងល្បើកឡាហ្វុងតែន រឿងអ្នកកាប់អុសនិងមច្ចុរាជបញ្ជាក់ពីការខ្លាចងាប់របស់ជនតោកយ៉ាកម្នាក់។ ក្នុងគុកកាមកិលេស របស់លោក កេង វ៉ាន់សាក់ មានបញ្ជាក់ថា (តែមនុស្សមិនព្រមស្លាប់សោះឡើយ អូនអើយស៊ូរស់ចាស់ជរា ក្នុងខ្ទមភក់ជ្រាំទ្រាំវេទនា ឲ្យតែការពារជីវិតបាន)។ ដោយមនុស្សមិនអាចអាចស្គាល់ងាប់ច្បាស់ យើងអាចប៉ាន់ថា ដែលមនុស្សភ័យខ្លាចមែនទែន គឺភ័យនិងខ្លាចពេលហៀបងាប់ ព្រោះពេលនោះរឿងចាស់ទាំងប៉ុន្មានលេចចេញឯកឯងពីក្នុងមក ដោយគ្មានកម្លាំងក្រៅខ្លួនណាមួយជួយទប់បាន។ ជាឧទាហរណ៍៖ មនុស្សខ្លាចប្រកាច់ប្រកិន ខ្លាចទៅហើយមកវិញៗ ខ្លាចដង្ហក់ កន្ទ្រាក់ទ្រើកៗ ឬបើកភ្នែកក្រឡោត ក្រឡោតខ្លាចគេនិយាយដើម។ល។

ព្រោះមនុស្សខ្លាចងាប់នេះហើយ ទើបសាសនាខ្លះពោលបណ្តោយថា មិនអីទេងាប់ហើយកើតវិញៗ...... នេះដើម្បីជួយលើកទឹកចិត្តឲ្យមានសង្ឃឹម ឬកុំឲ្យភ័យពេកពេលហៀបងាប់។ តែមនុស្សខ្លះដឹងរឿងពិត ក៏នៅតែខ្លាចដដែល។

យើងសរសើរ ក្រឡាហោមគង់ សូក្រាត(ដែលសុខចិត្តនៅងាប់ដោយមិនព្រមរត់គេចខ្លួន) យក្សកុម្ភកាណ៌ក្នុងរឿងរាមកេរ្តិ៍ យើងសរសើរជនដែលហ៊ានដុតខ្លួនឯង យើងសរសើរវិរជន...។

ពីព្រោះមនុស្សខ្លាចងាប់ទៀត ទើបទស្សនវិទូទាំងឡាយដែលខំរកសុខឲ្យមនុស្ស បានប្រឹងរកផ្លូវឲ្យមនុស្សងាប់ ៖ ចេះងាប់ ឬ ចេះទទួលការងាប់ គឺជាការសម្រេចសុខមួយ ពិសេសសុខពេលហៀបងាប់។ ជនដែលខំប្រព្រឹត្តល្អក្តី ខំរកសុខឲ្យគេក្តី សុទ្ធសឹងជាអ្នកដែលខំមិនញញើតការងាប់។ ជនទាំងនោះតែងគិតដូចព្រះពុទ្ធដែរថា (អំពើល្អ គេគប្បីសាងឲ្យហើយនៅ

ថ្ងៃនេះ ព្រោះគ្មាននរណាអះអាងបានថា ខ្លួនពិតជាមិនស្លាប់នៅថ្ងៃស្អែក)។ ដូចនេះ ចង់ធ្វើទស្សនវិជ្ជា គួររៀនងាប់ឲ្យហើយ។ ការរៀនងាប់ នាំឲ្យយើងមិនងាយបោះបង់គោលជំហរផង (ឧ. ក្លាលីលេ ដែលសុខចិត្តជាប់គុកអត់បាយ ព្រោះមិនព្រមឆ្លើយថាផែនដីសំប៉ែត ឬ ផែនដីនឹង) នាំឲ្យជីវិតយើងទៅដល់គំរូដល់គេផង ហើយបើហោចណាស់ក៏នាំឲ្យយើងមិនភ័យស្លុតប្រកាច់ប្រកិន ពេលហៀបងាប់នោះដែរ ពិសេសនៅសតវត្សដ៏ងាប់ផុតនេះ។ អ្នកប្រាជ្ញពោលថា (គេងាប់ថ្លៃថ្លា។ កាលណាគេមិនងាប់ មុនពេលត្រូវងាប់)។

★ ★ ★

## ធ្វើការឡើង

ការ ជាដើមសប្បាយមែនទែន។ ចិត្តសើៗតែខំស្វែងរកសប្បាយតែគេមិនបានសប្បាយមែនទែនទេ គឺជួបត្រឹមសប្បាយសើៗ ឬសំបកសប្បាយប៉ុណ្ណោះ។ សប្បាយ ឬ សុខ មែនទែននៅត្រង់យើងខំបង្កើត ឬសម្រេចគំនិត ឬការគាប់ប្រសើរធំៗណាមួយឲ្យបាន ទោះជួនកាលវេទនាខ្លួនខ្លះ ឬខាតខូចកិត្តិយសផ្ទាល់ខ្លួនក៏ដោយ។ គេមិនគួររត់រកសប្បាយទេ តែគួរសប្បាយដោយខំធ្វើការ។ ជួនកាលភាពចាំបាច់នៃការ បានឃាត់មនុស្សឲ្យខ្ជិលលំហែ។ ចិត្តធំៗ ជ្រៅៗខ្លះ សម្រាក ឬ លំហែម្តងម្កាលដោយសារចៀសមិនរួចប៉ុណ្ណោះ ព្រោះឃើញបរិយាកាសនៃភាពទំនេរ ដូចទទេល្វឹងគួរឲ្យព្រឺ ព្រះពុទ្ធត្រាស់ដឹងដល់ចូលនិព្វាន មួយថ្ងៃៗធ្វើការដោយសម្រាកយ៉ាងតិចបំផុត ពេល៤៥ឆ្នាំ។ លោក ហ្លូប៊ែរ ស្មេរបារាំងនៅសតវត្សទី១៩ ពេលសរសេររឿងប្រឌិតចុងក្រោយមួយ បានធ្វើការប្រាំបីថ្ងៃប្រាំបីយប់ជាប់គ្នា ដោយដេកតែដប់ម៉ោង លោកលីត្រេ ស្មេរវេចនានុក្រមបារាំងបានធ្វើការមួយថ្ងៃដប់ប្រាំបីម៉ោងងស់រយៈពេលម្ភៃបីឆ្នាំ ហើយលោក ឡារូស ត្រូវខ្សោះខ្លួន ដោយសារការដ៏ធំដូចគ្នានេះ។

ការនាំឲ្យឃ្លាតអផ្សុក ឃ្លាតក្តីបារម្ភ ចំណង់ផ្តេសផ្តាស ជំងឺ និងបទល្មើសផ្សេងៗ ហើយការល្អប្រសើរ មិនចាំបាច់មានការងារ ការងារ នោះទេ តែគឺការដែលកើនឡើង ៖ ឡើងពីកម្លាំង

បាយទៅការខួរ ឡើងពីដដែលៗទៅថ្មីប្លែក ឡើងពីការជាប្រយោជន៍ខ្លួន ទៅជាការប្រយោជន៍គេ ឡើងពីងាយធម្មតាទៅតឹងៗ... ធ្វើការឡើងហើយកុំធ្វើការចុះឲ្យសោះ! ផ្លូវមានតែមួយដើម្បីសុខវែងឆ្នាំ។

★ ★ ★

# សម្រស់ជីវិត

សំណាងធំណាស់កើតជាមនុស្ស...

បណ្ដាលសត្វលោក យើងនេះហើយដែលស្គាល់ស្អាតស្គាល់ល្អ ស្គាល់សិល្ប៍ ចេះប្រមើ-ល ចេះគ្រោង ចេះសម្រួលការរស់ឲ្យបានស្រួលឡើងៗគ្រប់បែបយ៉ាង។ យើងនេះហើយដែល (ស្លាប់នឹងជាគឺអស់ចិត្ត)។ សត្វមិនចេះព្យាបាលរោគខ្លួនឯងទេ មិនស្គាល់ព្រូន ស្គាល់អាចម៍ ស្គាល់មេរោគទេ ធ្វើដំណើរតែនឹងជើង ឬ ស្លាប គ្មានផ្លូវទប់ទល់ចំពោះភាពក្ដៅរងារញ័រញាក់ ឬកំហឹងធម្មជាតិ... ហើយដោះស្រាយតាមតែកម្លាំងបាយដែលឲ្យផលតិចតួចប៉ុណ្ណោះ សត្វគ្មានខ្លុយឃឹមចាប៉ីស្គរ កុនល្ខោន វិទ្យុទូរទស្សន៍ គ្មានអុក រែកបាល់សី ពីប៉ុង នំក្រូច នំគ្រក់ នំចៀន គ្មានសៀវភៅរឿង សៀវភៅរូប ដូចយើងទេ...។ យើងសប្បាយជាងសត្វច្រើនណាស់ យើងសុខស្រួលនិងស្រស់ជាងសត្វច្រើនណាស់... ធម្មជាតិទាំងមូលជារបស់យើង... ពិសេសធម្មជាតិផ្ដល់លក្ខណៈប្រសើរៗឲ្យយើងច្រើន... ។

ដៃ ជើង សាច់ស្បែក ភ្នែកត្រចៀកច្រមុះមាត់ សួតថ្លើម បេះដូងក្រពះពោះវៀនរហូតដល់ខួរក្បាល សុទ្ធតែមានតម្លៃទាំងអស់ នឹងល្អទាំងអស់ ទឹកមាត់ដែលគេថា ធុំក្លិនអាក្រក់ ក៏មានតម្លៃខ្លាំងដែរ ដូចជាឲ្យអាហាររលាយស្រួលក្នុងរាងកាយ។ ទឹកនោម និង អាចម៍ បើធ្អេះស្អុយក៏យើងមានគ្រឿងប្រដាប់បញ្ចេញចោលតាមទំនងដែរ។ ក្រៅពីស្វាដែលមិនជាណាស់ណាប៉ុណ្ណាមានតែយើងគត់ដែលអាចប្រើម្រាមដៃយ៉ាងប៉ិនប្រសប់បានច្រើនបែបយ៉ាង។ បើមានអ្នកខ្លះមើលឃើញថាសាច់ឈាមមុខមាត់ ដៃជើងនឹងខ្លួនប្រាណ សុទ្ធតែអាក្រក់ក៏អ្នកនោះមិនដាច់ចិត្ត

ឲ្យគេកាត់ចោលដែរ... ទោះអវៈយវៈនោះពិការក៏មិនដាច់ចិត្តដែរ វៀរលែងតែចៀសមិនរួច។ ធម្មជាតិ វិទូរកឃើញថារាងកាយមនុស្ស ជាគ្រូពេទ្យមួយពេញគ្រប់គ្រាន់ក្នុងការទប់ទល់ជំងឺ ឬមេរោគផ្សេងៗ។ វិជ្ជាពេទ្យ ពេទ្យនិងថ្នាំពេទ្យ គ្រាន់តែជាជំនួយ ឬជាគ្រូពេទ្យទីពីរប៉ុណ្ណោះ។ ក្រៅពីនេះយើងមានសម្បត្តិដ៏ស្កុកស្កម្ភដ៏ថ្លៃ និងដ៏កំពូលមួយទៀត គឺ គំនិតបញ្ញា។

គំនិតបញ្ញា នាំឲ្យជីវិតល្អិតមួយដែលមានកំពស់ត្រឹមជាងមួយម៉ែតមានទំងន់ត្រឹមហាហុកសិនគីឡូ មានត្រចៀក ភ្នែកច្រមុះនិងវិញ្ញាណ អន់ជាងសត្វស្លាប ឬជើងបួនខ្លះដូចមេឃនិងដី... ទៅជាអាចបង្កើតនិងសម្រេចបានទង្វើដ៏សម្បើមៗ ដ៏មានតម្លៃៗ ដ៏កំពូលៗដ៏ហួសស្មាន... រាប់មិនអស់។ មនុស្សចេះច្រើនណាស់ ... មនុស្សដឹងច្រើនណាស់... ច្រើនណាស់... ច្រើនឡើងៗ ជ្រៅឡើងៗ ។ ហើយមនុស្សបានដោះស្រាយរឿងលំបាកវេទនារបស់មនុស្សបានច្រើនណាស់... ច្រើនរាប់មិនអស់។ ជម្ងឺសាហាវៗ ជាច្រើនមានអុតអាសន្នរោគ ប៉េះនិងរបេងជាដើមបានវិនាស ឬ បាក់កម្លាំង។ រនាំងជីវិតជាច្រើនមានភ្នំទន្លេសមុទ្រ ធាតុអាកាសក្តៅត្រជាក់ ។ល។ បានត្រូវមនុស្សទំលុះទំលាយរួច។ ចលនាដំណើរបានប្រែប្រួលដល់កំពូល ដោយសារកង់ម៉ូតូ រទេះ ឡាននិងយន្តហោះ ហើយការទាក់ទងគ្នាក៏ឃើញឆាប់ទាន់ចិត្តតាមរយៈទូរស័ព្ទ ទូរលេខនិងប្រដាប់ទំនើបឯទៀត។ គឺគំនិតបញ្ញានេះហើយដែលនាំឲ្យមនុស្សលូតខ្ពស់ឆ្ងាយពីសត្វដទៃបន្តិចម្តង រហូតហៅមិនឮ ។ ប៉ុន្តែអ្នកដែលមានទស្សនៈ ខ្មៅ ឬទុទិដ្ឋិនិយម មើលឃើញផ្ទុយផ្សេងទៅវិញថា ការលូតចម្រើននេះជាកាំបិតចិតដងឯង។

គេថាដោយសារគំនិតបញ្ញាការចេះដឹងលូតលាស់ និងវិទ្យាសាស្ត្រជឿនលឿនទំនើបឡើងៗនេះមនុស្សមានបញ្ញាស្មុគស្មាញក្រវេមក្រវាមស្អេកស្កះជិះជាន់កាប់សម្លាប់ សង្កត់សង្កិន ប្រើល្បិចកិច្ចកល បោកប្រាស់ ធ្វើទុក្ខ ធ្វើបាបគ្រប់សព្វបែបយ៉ាង ហើយសាហាវឡើងៗ។ សីលធម៌ មនុស្សធម៌ធ្លាក់កំរិតចុះយ៉ាងទាប... ទាបជាងសត្វ ហៅមិនឮ ៖ សត្វបើកាចក៏ត្រឹមមួយផ្លែត ហើយគ្មានកិច្ចកល គ្មានលាក់លៀម លាក់ទុក បោកប្រាស់ សម្លាប់រង្គាល ឬសម្លាប់ព្រៃផ្សៃ ដូចមនុស្សស៊ីវិល័យដែរ... ពិភពលោកហាក់ចាំតែថ្ងៃវិនាសប៉ុននោះ... ពិភពលោកគ្មាន

ផ្លូវសង្ឃឹមទេ។ ប៉ុន្តែយើងគួរសួរថាហេតុអ្វីក៏អញ្ចឹង? ដោយសារវិទ្យាសាស្ត្រឬ? ដោយសារគំនិតបញ្ញាឯងឬ? ឬក៏ដោយសារសង្គមមនុស្សរៀបចំមិនទាន់ស្រួល...។

គេថារោគស៊ីវិល័យ រីកសាយឡើងៗ បង្ខិនសត្វធាតុ ទឹកខ្យល់ឲ្យវឹងទៅនិងខូចទៅ។ ក្មេងៗ កើតប្រិចអាយុបួនដប់ម្លៃឆ្នាំមិនទាន់ ក៏ដុះគំនិតផ្ដេសផ្ដាសទៅហើយ។ មនុស្សផ្ដេសផ្ដាសឡើងៗលែងស្គាល់ចាស់ស្គាល់ទុំ ស្គាល់មាមីង ស្គាល់បងប្អូនក្មួយ ស្គាល់សិស្សស្គាល់គ្រូ មនុស្សគិតតែពីអញៗៗ ឆ្អិនក្បាលស៊ីសក្បាល ឆ្អិនកន្ទុយស៊ីកន្ទុយ...។ ប៉ុន្តែតើយ៉ាងនឹងទាំងអស់គ្នាឬទេ? ឬក៏មានមនុស្សល្អប្រសើរច្រើនដែរ... ហើយហេតុអីក៏យ៉ាងនឹង? ដោយសារវិទ្យាសាស្ត្រឬ... ឬក៏ដោយសារសង្គមមនុស្សរៀបចំមិនទាន់ស្រួល...។

មនុស្សច្រើនណាស់គ្រាន់តែអស់សង្ឃឹម រឿងផ្ទាល់ខ្លួនមួយពីរ ពិសេសរឿងស្នេហាតែម្ដង ក៏តាំងចិត្តគិតយល់ប្រកាន់ថាពិភពលោកនេះស្អុយឆ្អេះឆ្អាបពោរពេញដោយទុក្ខសោកសៅហ្មង រកសុខមិនបាន រកទ្រាំមិនកើត រកល្អមិនឃើញ រកន័យគ្មាន (គឺមិនដឹងជាអ្វី) ។ល។ យល់បែបនេះគ្មានលក្ខណៈទូទៅទេ។ ជាកំហុសមួយ ប្រសិនបើទាស់នឹងមនុស្សម្នាក់ពីរ ឬឃើញមនុស្សអាក្រក់ម្នាក់ពីរ ឬក៏ឃើញមនុស្សផ្ដេសផ្ដាស់មួយកន្លែងពីរ ហើយសន្និដ្ឋានថាមនុស្សតែអាក្រក់ទាំងអស់ (ចំពោះរឿងស្នេហា បើមានណាត់ជាមួយគេម្នាក់ដោយគ្មានសង្ឃឹមថាបានជួបនោះយើងអាចបង្វែរចិត្តឲ្យតោងឬឈោង ទៅគេម្នាក់ទៀតដែលមានរាងរៅ និងឬកពាស្រដៀងគ្នា ៖ ជួស របៀបនេះ អាចនាំឲ្យជា និង មានសង្ឃឹមវិញ វៀរលែងតែគេមានទោស គឺមានតែមួយគត់ក្នុងលោក... ពេលនេះមិនដឹងធ្វើម៉េច ទ្រាំតាមកម្ម ដោយខំកាត់ចិត្តបន្តិចម្ដងទៅចុះ... តែទូទៅកម្រមានតែមួយគត់ណាស់...)។

មនុស្សច្រើនណាស់ បានខ្វល់និងខំរកន័យឲ្យជីវិតរហូតចេញជាទ្រឹស្ដីផ្សេងៗ។ បើការខំរកនាំឲ្យមនុស្សថយទុក្ខសោក នោះជាការប្រសើរណាស់។ យើងពុំហ៊ានយល់យ៉ាងណាៗទេ ព្រោះសូម្បីតែពាក្យ (ន័យ)នេះយើងពុំដឹងមានន័យសេចក្ដីចង់ថា យ៉ាងណាច្បាស់លាស់ផង។ ព្រះពុទ្ធពេលមាលុង្គបុត្តសួរថា (មានធម៌ខ្លះ ដូចរឿងស្លាប់ហើយកើតវិញ ឬមិនកើតជាដើម បើ

ព្រះអង្គមិនសម្តែងឲ្យដឹង ខ្ញុំករុណាមិនបួសក្នុងសាសនាព្រះអង្គទេ) បានឆ្លើយទៅវិញថា (មនុស្សម្នាក់ត្រូវគេបាញ់ បើរវល់សួរថានរណាបាញ់ បាញ់ពីខាងណាដោយហេតុអ្វី ទាល់តែដឹងសិនទើបព្រមឲ្យព្យាបាលនោះ អ្នកនោះស្លាប់មុននឹងមិនខាន...) យ៉ាងណាមិញ ជីវិត បើខំដោះទុក្ខដែលចោទជុំទិសឲ្យទាន់ពេល ប្រហែលប្រសើរជាងការខំប្រឹងខ្វល់គិតរកន័យ...។ ប៉ុន្តែរកន័យនេះទៀត (ឃើញក្តីមិនឃើញក្តី) ក៏ព្រោះមនុស្សមានគំនិតបញ្ញាដែលនាំឲ្យខ្លួនខ្ពស់ជាងសត្វដែរ... បើមិនហ៊ានថា ស្រស់ជាងសត្វ។

កិច្ចការរបស់មនុស្សទៅ របស់អ្នកប្រាជ្ញ អ្នកគ្រប់គ្រង អ្នកអប់រំ និងរបស់អង្គការពិភពលោកផ្សេងៗ តាំងពីរដើមមកមានបំណងធំដោះស្រាយបញ្ហា សព្វយ៉ាងរបស់មនុស្ស តាំងពីគ្រោងទុក ការពារមុននឹងព្យាបាលភ្លាមៗ រហូតដល់រកផ្លូវបណ្តុះឲ្យចម្រើនតាមអាច ដើម្បីលែងឲ្យមនុស្សបានសុខសប្បាយនិងស្រស់ឡើងៗ។ ពេលនេះប្រទេសខ្លះ បានជួបភាពរីករាយប្រាកដទៅហើយ ហើយពេលក្រោយដោយសារការខំប្រឹងប្រែងស៊ូរបស់ខ្លួន មនុស្សមុខជាអាចចូលដល់ដំណាក់មួយដែលបញ្ជាក់ប្រាប់ខ្លួនវិញថា ជីវិតពិតជាសម្រស់ម្យ៉ាងនាំឲ្យអ្នកខ្លះលែងចង់លាចាកពិភពលោកទៀត។

★ ★ ★

កំណាព្យ

## ចោលគេភ្លើខ្លងហាង

១. អៀនដៃកន្លងមួយដងនោះ ចង់ស្ទុះចេញភ្លាមពីកន្លែង

លោកអ្នកមើលខ្ញុំហួសនឹងថ្លែង ព្រោះរឿងលុយឯងដែលនាងអាប់។

២. ហាងនោះថាហ៊ឹបក៏ថាបាន ម្ហូបម្ហាប៉ុន្មានគ្មានឆ្អិនស្រាប់

ទាំងនាងកាន់ចានក៏ចំណាប់ ទាំលុយដែលអាប់ក៏ហឹបដែរ។

៣. ខ្ញុំយកប្រាក់ខ្ញុំគ្រប់ទេតើ ម្ដេចស្រីមុខស្មើលែងស្និទ្ធស្នេហ៍

ម្ដេចលោកអ្នកនាងមើលខ្ញុំដែរ ខ្ញុំខ្មែរបូរាណមិនបានដឹង...។

★ ★ ★

# ស្រឡាញ់កវី

១. ខ្ញុំស្រឡាញ់ អស់លោកអ្នកកវីធំ យំមុនគេសើចក្រោយគេជាធម្មតា

ឃើញព្រៃភ្នំហាក់ស្រែកយំជួសមនុស្សា តែងប្រាថ្នាឲ្យសព្វសត្វបាត់ទុក្ខសោក។

២. ខ្សែជីវិតជិតដាមជាប់ដោយពាក្យចួន ខំផ្ទឹមផ្ទួនផ្ទុយផ្ទាស់ផ្ទាល់រឿងមនុស្សលោក

នាំអ្នកផងឲ្យអរកើតភ័យវិយោគ បានជ័យជោគត្រឹមស្លាប់ទៅនៅវាចា។

៣. ខ្ញុំស្រឡាញ់ការផ្សេងព្រេងតាមដងព្រៃ ភ្នែករំពៃមើលភូមិស្រុកស្រែចំការ

មើលមេឃដីទឹកសមុទ្រខ្យល់សុទ្ធថ្លា ហ្វូងបក្សាច្រៀងរាំរេបំពេរកាយ។

៤. ខ្ញុំចូលចិត្តត្រាច់រង្គត់កាត់ទុក្ខព្រួយ ពីទីមួយទៅពីមួយទៅឲ្យឆ្ងាយ

ទៅឲ្យផុតពិភពភ័យផងទាំងឡាយ ទៅសប្បាយសុខក្សេមខ្សាន្តក្នុងឋានស្ងប់។

៥. ខ្ញុំស្រមៃឃើញឋានមួយភ្លឺសោភា ដូចចន្ទ្រាថ្លាត្រជាក់ចាំងសាយសព្វ

គេស្នេហ៍គ្នាគេសុខជាស្អាតមួយចប់ មិនធុញថប់ចាប់ទាបតូចដូចផ្ទះខ្ញុំ។

★ ★ ★

# លោកនេះលឿនណាស់

១. លោកនេះលឿនណាស់ច្បាស់ក្រឡែត ត្រដែតហួសហេតុទាយលែងត្រូវ
ពីមុនមានកង់ខ្ពង់ពេកកូវ ឥឡូវបើកឡានលែងបានខ្វង់។

២. លោកនេះលឿនណាស់លឿនផុតលេខ គ្មានខ្វះស្ពះស្អែកត្រេកតាមចង់
ចំណេះចេះខ្ទេចលេចឡើងឆ្ងង់ អ្នកផងកោតខ្សង់ត្រង់គ្មានតឹង។

៣. ថ្ងៃនេះបេះដូងគេដូរកើត ស្អែកឆើតដូរកក៏មិនដឹង
ថ្ងៃនេះជិះខែដូចគ្មានប្រឹង ស្អែកណឹងដល់ណាថាមិនបាន។

៤. តែលោកលឿនពេកលូតរ៉េវពេក ខ្ញុំក្រែងឆាប់ដេកដួលអស់ប្រាណ
ក្រែងល្បីខាងមុខថ្មីថ្កើងថ្កាន ខាងក្រោយពុំក្សាន្តកើតទុក្ខភ័យ។

៥. ម្យ៉ាងលូតរីកណាស់(រឿង)ក៏ណាស់ ធាតុផ្សំប្រើប្រាស់ខ្វះហូរហៃ
ខ្វះព្រៃទឹកដីត្រែដែករ៉ែ នៅតែចិត្តមនុស្សស្ទុះពុំស្កប់។

៦. ពីមុនចូលឆ្នាំពេញមួយខែ ស្រុកស្រែទេសនាទសជាតក៏ចប់
រីករាយក្អាកក្អាយសប្បាយសព្វ ឥឡូវត្រឡប់ត្រឹមបីថ្ងៃ។

៧. ពីមុនប្រុសអន់ដណ្ដឹងស្រី ថ្មីៗស្រីអន់ប្រុសឡើងថ្ងៃ
ពីមុនឱតគ្នាឮតិចក្រៃ ក្មេងៗសម័យប្រិចចេះភ្លាម។

៨. ពីមុនមនុស្សហាក់ត្រង់ល្អជា ឥឡូវទាស់គ្នាឮរវាម
ជិះជាន់ស៊ីឡឹបគ្មានទីមទាម បាញ់ចាក់ហូរឈាមជាធម្មតា។

៩. ផែនដីដ៏ធំមនុស្សក្លាប់បាន ខ្ញុំដេកនឹកស្មានថ្ងៃមួយណា
មនុស្សលឿនដល់ថ្នាក់ក្លាប់មនុស្សា ចាត់ការប្រល័យក្ស័យយ៉ាងនៅ។
១០. លោកនេះលឿនណាស់ឃោឃៅណាស់ ក្រឡិចក្រឡាស់ឃើញក្រឡៅ
រស់ក្នុងកលិយុគ[1] យុគហ្មងសៅ ចិត្តខ្មៅក៏លូតលឿនណាស់ដែរ។
១១. តែខ្ញុំសង្ឃឹមលើសីលធម៌ ក្ដីល្អដែលមនុស្សច្រើនគ្នាស្នេហ៍
ចិត្តស្អាតចម្រើនកើនហូរហែ កែលោកឲ្យលូតផុតកលិយុគ។

★ ★ ★

## អាសូរឃាតផ្ទះ

១. ពួនស្ងាត់បាត់រូបកណ្ដាលដី ទ្រផ្ទះធំថ្មីឲ្យសង្ហា
ឲ្យជាប់ខ្ពង់ខ្ពស់ឈ្មោះថ្លៃថ្លា គេថាសំណង់សង់សែនល្អ។
២. គេអួតថាសឿងគ្រប់គ្រឿងលើ ពីដែកដល់ឈើដល់គ្រួសថ្ម
គ្រង់គ្រឹះគ្រមឹះក្រោមសសរ គ្មានគេមាត់កគិតមេត្តា។
៣. ពេលផ្ទះឈរស្វែតជាប់មាំមួន គ្រឹះបានរួចខ្លួនពីគេថា
ដល់ផ្ទះបាក់បែកស្រុតអាត្មា គេថាគ្រឹះអន់គេស្ដីជេរ។
៤. ប្រសើរបើគ្រឹះមានជីវិត តើអ្នកនឹងគិតស្រែកប្រាប់គេ

[1] ជំនឿព្រាហ្មណ៍ចែកកាលជា ៤ យុគ ៖ យុគទី៤ចុងក្រោយឈ្មោះ កលិយុគចាប់ផ្ដើមពីឆ្នាំ ១៣០២ មុន គ.ស រហូតវិនាស ផែនដី ៖ កលិយុគនេះមនុស្សអាក្រក់អស់បីភាគនៅល្អតែមួយភាគ...

ឲ្យមើលមកអ្នកដែរឬទេ ព្រោះអ្នកជាមេឲ្យគេថ្កើង។

★ ★ ★

## ជីវិតឡានឡូ

១. គេដោះគេដូរគេដាប់ដំ គេរើរៀបចំជាធម្មតា

ក្រុមជាងជួសជុលកើនកិច្ចការ ដោយសារឡានចាស់ផ្លាស់មិនចប់។

២. កូនឡានកម្សត់ហត់ចូលហាង សំណាងយូរម្ដងគេលាងដី

ពាសបាតប៉ាតពណ៌រលើបខ្ទី ប្រិមប្រិយសម្បើមសំបកក្រៅ។

★ ★ ★

## វិមានអភ័ព្វ

១. តាមព្រៃភ្នំកោះតាមមាត់ទឹក ឃើញភ្លឹកឃើញនឹកឃើញបេតី

វិមានតូចធំស្រស់ប្រិមប្រិយ ថៃមសួនខៀវខ្ចីដូចឋានសួគ៌។

២. វិត្ថុប្រើប្រាស់មានគ្រប់យ៉ាង មានថ្មីស្រឡាងរៀបជាជួរ

មានមកពីនាយថ្លៃហួសគួរ ពេញតួលួងកប្លែកអាត្មា។

៣. តែផ្ទះថ្មីខ្ទង់សង់សមល្អ គ្មានឮមាត់កដូចធម្មតា

ឃើញត្រឹមព្រៃសត្វសព្ទខៀវខ្ចា ជីវិតខ្លោចផ្សាហាលភ្លៀងក្ដៅ។

៤. យូរៗឃើញមានមនុស្សម្នាក់ពីរ វកវីរដុសលាងជូតក្នុងក្រៅ

ថៃធ្លាថៃច្បារកាច់ផ្កាស្មៅ ក្រែងថ្ងៃសុក្រសៅរ៍ម្ចាស់មកជិត។

៥. គេសង់ទុកចោលតាមធនធាន វិមានរងព្រួយមួយជីវិត

បួងសួងឲ្យម្ចាស់មករួមរឹត អ្នកផងខ្លះគិតអាណិតស្តាយ...។

★ ★ ★

# ជីវិតមាន់ជល់

១. ស៊ីឆ្ងាញ់តាមឃ្លានមានដេកមុង មានចាក់ថ្នាំគង់រុងរឿងកាយ

ម្ចាស់ថ្នមបីបមលោះនឿយណាយ សមបានសប្បាយឆ្ងាយមាន់ស្ល។

២. ដែលរស់ឯកឯងក្រែងក្រឌី ក្រែងខ្លាំងអប្រិយ៍គ្មានក្តីល្អ

ក្រែងថ្ងៃអន្សាគេអារក ខានតល្វាវច្បាស់ធ្លាប់ដាស់គេ។

៣. តែមាន់ដេកម្លងជាប់ទ្រុងជាល ក្រៅ(វាលសៃរៀន)គ្មានវាលទេ

គេជល់មើលជុំគ្មានទំនេរ គ្មានពេលរិះរេថាគេឯង។

៤. ជល់ញាប់ជល់ញ័រជល់តាមញាក់ ថ្ងៃក្តៅត្រជាក់ភ្លៀងហួតហែង

ល្ងាចព្រឹកគ្មានឈប់គ្រប់កន្លែង ចាញ់ឈ្នះជាក់ស្តែងជាធម្មតា។

៥. ញឹកឈ្នះញឹកម្ចាស់គេថ្នម រីងរាងប្រិមប្រិយឈ្មោះសង្ហា

ពងកូនកើតប្រិចគេប្រាថ្នា ជល់ចាញ់លែងក្លាជល់ស្រា ស។

៦. ប្រឹងជល់គ្នាឯងមួយជីវិត ជួសគេទាំងល្ងិតដោយត្រេកអរ

គេឈ្នះបានលុយចាញ់បានស្ល មាន់បានដាច់កគ្មានគេកប់។

# ឃើញខ្ញុំសខ្លួនឯង!

១. ខ្ញុំខុសអ្វីម្ល៉េះពុំចេះអស់ ចង់ស្រស់ចង់ស្រើបចង់ស្រីស្រា
ចង់កើបទាំងខ្វិលធ្វើកិច្ចការ ចង់ឈ្មោះថ្លៃថ្លាទាំងឆ្ងាយសីល។

២. ខ្ញុំខ្វង់គ្មានខ្មាសមីងមាស្រែ មិនឃើញពាក្យខ្មែរដែលចេះប្រិល
ចូលចិត្តអ៊ីអ៊ុយស្ទើរអិល អណ្ដាតរិលៗអួតចេះសត្វ។

៣. ពេលណាសម្ដែងបានពីរបី សម្ដីខ្ញុំហាថាបានដប់
ជួបញាតិខ្ញុំប្រាជ្ញ(អាចមួយចប់) ឬកកប់រាងកប់មិនព្រមប្រឹង។

៤. ខ្ញុំគ្មានគំនិតគិតហេតុផល គ្មានភ្ញាក់គ្មានឆ្ងល់គ្មានចង់ដឹង
គេកេះថាអន់ខ្ញុំអៀនខឹង គេដឹង... បញ្ជោរ... ខ្ញុំហ៊ោអរ។

៥. ខ្ញុំអន់ឃើញធ្មិនថាជានៅ ឃើញខ្មៅក្រៃណាថាជា ស
ដឹងច្បាប់ថាល្បែងតែងច្បាម ក តែខំត្រដរ(ឈប់បបូរ)។

៦. ពេលមួយពួយផ្ទុយពាក្យស្ដេច ខំត្រាច់រកឈ្នះកាស៊ីណូ
ចាញ់លង់អស់លុយអង្គុយថ្ងូរ ឡាន កង់ ម៉ូតូ... លក់លេងអស់។

៧. ខ្ញុំខុសមិនចប់ចង់ខូចចិត្ត ខុសធំតូចល្អិតឃើញស្រស់ៗ
រស់មុខមិនរីករវែងក្រៀមក្រោះ ស្រណោះខ្លួនដៃរកែមិនឡើង។

★ ★ ★

# អាសូរហ្សឹបសូត្រ[2]

១.	ហ្សឹបអើយហ្សឹបសូត្រសរសៃទន់	បានកាន់បានគន់... កើតវះកាត់
	ស្រួលដុះស្រួលប្រើប្រសើរឥត	ច្រាសផងរៀបជិត... រឹតឃើញល្អ។
២.	ហ្សឹបសូត្របើសាកបីបួនព្រឹក	ចិញ្ចាញលែងសឹកធ្មេញឡើងស
	តែហ្សឹបស៊យណាស់ខ្មែរនៅក្រ	នៅស្ទើរអង្គរមិនហ៊ានស្ទាប...។

★ ★ ★

# ព្រួយបន្តិច

១.	ខ្ញុំសប្បាយព្រោះបានឃើញគេសាងជាតិ	ជួយញោមញាតិឲ្យឃ្លាតចាកក្តីវេទនា
	ជួយឃិតឃោងឲ្យរាស្ត្រយើងយល់វិជ្ជា	លែងដៀលគ្នាថាល្ងង់ខ្លៅក្រយៅស្រែ។
២.	ខ្ញុំពីរោះព្រោះឮច្រៀងចំរៀងជាតិ	ដាស់ញោមញាតិឲ្យខ្មីឃ្មាតគិតមកខ្មែរ
	ដាស់ក្មេងក្មាងឲ្យដេញខ្មាំងរាល់ថ្ងៃខែ	ខ្លាចក្មេងបែរទៅបៀបារស្រានិងស្រី។
៣.	ខ្ញុំព្រួយចិត្តត្បិតកុនខ្លះបែប(ណាស់)ជ្រុល	បង្ហាញគល់បង្ហាញគូថកប់ណាណី
	ពង្វក់ក្មេងឲ្យភ្លើតភ្លើនភ្លេចស្មារតី	គ្មានប្រណីគ្មានគិតគ្នាជាអ្នកគ្រាប់។
៤.	ខ្ញុំព្រួយចិត្តត្បិតបារខ្លះបើកទាំងថ្ងៃ	នាំជើងដៃចិត្តអ្នកផងអន់ស្វាជាប់
	នាំទាស់គ្នាព្រោះមេរ៉ាកើតចាក់កាប់	ខ្ញុំចង់ប្រាប់ឲ្យគេដឹងថាខ្ញុំព្រួយ។

[2] ហ្សឹបសូត្រ ជាម៉ាកច្រាស់ដុះធ្មេញដ៏ល្អដែលគេលក់ថ្លៃថយ ៦០រ នៅហាងរដ្ឋនិងលើស ៦០រ នៅហាងចិន។

# មេលេខទំនើប

១. មុន ពីរបីដងប្រាំមួយគត់ គេចាំរត់មាត់ពេញទឹកដី
ឥឡូវឮលាន់មេលេខថ្មី តិចណាស់ប្រាំបីទើបចំណាប់។
២. ចំណេះស្រស់ប្លែកសែនរំភើប ល្អលេខទំនើបល្អផុតច្បាប់
តែខ្ញុំខ្លាចក្រែងសិស្សបង្អាប់ ថារៀនស្ទើរស្លាប់គុណមិនត្រូវ។
៣. ពិភពលេខថ្មីលូនផុតឆ្ងល់ លូនដល់ក្រឡាប់សីលធម៌ល្អ
គេចេះគុណខ្មៅចេញបានស របៀនរបរសុទ្ធរបៀប។

★ ★ ★

# កឋិនវត្តយើង

១. ថ្ងៃនេះថ្ងៃល្អថ្ងៃកឋិន បុត្រព្រះផុតបិណ្ឌមានភស្តុភារ
ដែលបុទ្ធបរិស័ទ្ធមានសទ្ធា បូជាជាទានគ្នាខ្វះអ្វី។
២. ថ្ងៃនេះចាស់ទុំជុំក្នុងវត្ត តែភ្លាត់គឺត្រូវចាំឆ្នាំថ្មី
ខ្លះស្តាប់ធម៌អាថ៌បែបបាលី ខ្លះស្តាប់ភ្លេងថ្មីល្ខោនអាយ៉ៃ។
៣. ថ្ងៃនេះវត្តយើងមានវាសនា អាចារ្យជុំគ្នាគិតបច្ច័យ
ទុកសាងផ្សេងៗក្រៅអមត្រៃ កឋិនថ្លាថ្លៃបច្ច័យច្រើន។
៤. នៅថ្ងៃកឋិនដ៏បុណ្យទាន ខ្លះមានសន្ទូចទុកស្ទួចត្រី

មានទាំងកាំភ្លើងបាញ់បក្សី មានទាំងស្រាល្បីកំដរកាយ។

៥. ថ្ងៃបុណ្យកចិនល្អមើលក្តាត់ ខ្លះបាត់ស្បែកជើងគ្មាននឹកស្តាយ

ខ្លះឆ្អែតទាំងបុណ្យឆ្អែតទាំងបាយ ខ្លះទៀតតែងកាយចែកជួយញាតិ។

★ ★ ★

## នឹកយាយ

១. យាយខ្ញុំយាយចាស់ចូលចិត្តបួន ដាក់ខ្លួនក្នុងធម៌ក្នុងសីលទាន

ប្រាថ្នាឋានសួគ៌ឋាននិព្វាន កំហុសធ្លាប់មានបានស្មាលា។

២. តែយាយពេលមួយមមើប្លែក ដូចដឹងថាស្អែកអស់កម្មពៀរ

យាយហៅកូនចៅជួបជុំគ្នា ទឹកភ្នែកហូរហៀរហួសសព្វដង។

៣. យាយនឹកស្តាយវត្តឬនឹកចៅ? នឹកតានឹកចៅនឹកប្អូនបង

ដែលនៅមានកម្មមានចំណង មិនទាន់បានឆ្លងទុក្ខផែនដី។

៤. ឬយាយនឹកស្តាយសប្បាយស្រែ ដែលមានហូរហែលើលោកកិយ

លោកនេះគ្រើមគ្រង់គង់មានអ្វី ប្រិមប្រិយនាយឲ្យសប្បាយខ្លះ។

៥. ឬយាយខ្លាចកើតត្រឹមទេព្តា ឬស្នំស្នេហាព្រះឥន្ទ្រម្ចាស់

តែចៅដឹងច្បាស់... យាយនឹកតា។

★ ★ ★

# បុណ្យលោកស្រីម្នាក់

១. លោកស្រីល្បីស្រស់សម្រស់ឯក ជួបភ្លាមចិត្តប្លែកចង់ចងស្នេហ៍
ចង់លេបចង់ថើបចង់ថ្នមថៃ រាល់ថ្ងៃរាល់ខែដេកបេតី។

២. លោកស្រីល្បីស្រស់ហោះខោអាវ មួយឆាវដល់ភ្លាមដល់លោកស្រី
ថ្ងៃថោកពុំគិតគិតពីថ្មី អស់ចិត្តលោកស្រីទើបដល់ស្រែ។

៣. លោកស្រីល្បីសក់សែនរលើប ចូលហាងទំនើបជាប់ហូរហែ
ក្រចកជើងដៃហែណាស់ដែរ គ្មានចាំថ្នាំប្រែកែលាបទៀត។

៤. លោកស្រីល្បីថាសែនស្រណុក បាវព្រាវសំកុកគាល់ព្រោងព្រាត
ចង្ក្រានឆ្នាំងចានពុំដែលបៀត ជូនឆ្មៀតបាំងផ្លិតភ្លេងរបាំ។

៥. លោកស្រីល្បីម្យ៉ាងខាងមាសពេជ្រ ទាំងគ្រាប់ភ្លីលេចសុទ្ធត្បូងដាំ
ប្រាក់កាសកើតឯងអង្វែងឆ្នាំ ចៅទួតបួនប្រាំចាយមិនអស់។

៦. លោកស្រីល្បីម្យ៉ាងខាងថ្ងៃថ្នូរ ស៊ីក្លូម៉ូតូមិនជិះសោះ
គ្មានឡានស៊ូខានឫកសែនស្រស់ យន្តហោះក៏ធ្លាប់ភ័ព្វពេកពន់។

៧. ម្លឹងហើយលោកអើយខ្លះយល់ថា លោកស្រីនេះណាកាលជាតិមុន
មានរាងជាប្រុសខុសសែនធ្ងន់ រំលោភប្រពន្ធកូនចៅគេ...

៨. ទើបផ្លាស់កំណើតកើតជាស្រី រង់កម្មទូលប្តីគ្មានទំនេរ
តាមពិតពាក្យនេះខុសទេ ព្រោះឆ្អឹងមាសមេសែនសំណាង។

៩. ជាតិនេះលោកស្រីសាងអ្វីហ្ន៎? រំពឹងក្ដីល្អដូចគ្មានសាង
ហួរហែឃើញតែលុយឡានហាង សីលធម៌សព្វយ៉ាងគ្មានត្រូវការ។

១០. រំពឹងលុយឆ្នោត មិនឮត្រូវ រំពឹងកេរ្តិ៍ឪ ពិបាកថា
រំពឹងប្រាក់ខែ មិនណាស់ណា... អស្ចារ្យ! កុំឆ្ងាល់ផលលោកស្រី។

★ ★ ★

# យល់ខុសទេដឹង

១. បើមនុស្សគ្រប់គ្នាជាអាត្មូម ម្ដេចឡើយខ្លះបួមដោយមិនគិត
កាប់ចាក់ជិះជាន់ឲ្យភ័យភិត រឿងរ៉ាវជីវិតសែនខ្លោចចិត្ត។

២. រឿងមនុស្សគេថាវាធំវែង ខ្ញុំវិញច្បាស់ទែងវាតូចល្អិត
រស់តាមធម្មជាតិសែនប្រណិត មានច្បាប់កម្រិតមុនច្បាប់រដ្ឋ។

៣. មិនចាប់មាសប្រាក់ព្រំដែនដី ធ្វើអ្វីគ្មាន(ច្បាប់)ចាប់ឃុំឃាត់
ធ្វើការជុំគ្នាស៊ីស្មើមាត់ គ្មានវាត់ទូកស្នេកចែកកូនចៅ។

៤. រស់បែបបក្សីសែនប្រសើរ កូនណាចេះហើរបែកលំនៅ
រកស៊ីខ្លួនឯងមួយឆ្អែតទៅ រីករាយរាងនៅមិនសូវរឿង។

★ ★ ★

# កូនបណ្ដាំមួយ

| | | | |
|---|---|---|---|
| ១. | ពេលបងសូនប្រាណ | អូនអើយកុំខាន | ជួយយកទៅកប់ |
| | កៀនគល់កូនស្វាយ | ឲ្យសាយជាតិសប់ | កុំឲ្យបងចប់ |
| | | ក្នុងមឈូសឈើក្រាស់។ | |
| ២. | ព្រលឹងសប្បាយ | ដោយបានដើមស្វាយ | ផ្លែផ្កាដេរដាស |
| | បានទុកដីស្រែ | ឲ្យខ្មែរប្រើប្រាស់ | បានទុកដីស្រែ |
| | | សង់ផ្ទះញាតិផង។ | |
| ៣. | បងរស់មួយជាតិ | បង្ហិនសត្វធាតុ | ច្រើនក្រៃកន្លង |
| | អូនកុំទួញយំ | បុណ្យធំជាឆ្លង | ទុកឲ្យសត្វផង |
| | | សល់សុខខ្លះទៅ។ | |
| ៤. | ម៉ុងមេរុចេតិយ | តើបានផលអ្វី | ណាស្រីពាលពៅ |
| | បងក្លាយជាផេះ | រលេះរាងទៅ | បងគ្មានពេលនៅ |
| | | ក្នុងម៉ុងសោះឡើយ។ | |
| ៥. | សង្ឃឹមព្រលឹង | ក៏គ្មានរពឹង | ដែរណាអូអើយ |
| | យមរាជបានដៅ | ក្រយៅទៅហើយ | ឬមួយផុតស្បើយ |
| | | ឬមួយនរក។ | |
| ៦. | សែនព្រេនធ្វើអ្វី | ឆ្អេះឆ្អាបចំណី | ថានលើខ្ពើមភ្លក់ |

ចានប្រែតសាងខូច កំហូចគំរក់ កុំឲ្យស៊ីជក់

នាំចិត្តឡើយចាង។

★ ★ ★

សំបុត្រផ្ញើរជូនលោកគ្រូ **កេងវ៉ាន់សាក់**

**សូមជម្រាបគោរពលោកគ្រូ**

ម្ភៃឆ្នាំហើយដែលលោកគ្រូបានបង្រៀន និងស្រាវជ្រាវអក្សរសាស្រ្តជាតិប្រសិនបើគិតទល់ពេលលោកគ្រូឈប់បង្រៀននាំឆ្នាំ ១៩៦៨ ។ លោកគ្រូបានបង្កើតសាលាគរុវិជ្ជាមហាវិទ្យាល័យអក្សរសាស្រ្ត អង្គុលីលេខជាតិ ព្រមទាំងគំនិតជាតិនិយមក្នុងភាសា អក្សរ វេយ្យាករណ៍ វប្បធម៌ អរិយធម៌ និងក្នុងន័យចំណោះដទៃទៀតយ៉ាងច្រើន។ ខេមរយានកម្មសិក្សាជាផ្លែផ្កាមួយនៃកម្រិតនោះ។ ក្រៅពីគំនិតសមហេតុផល ត្រិះរិះពិចារណា ពិតនិយម ការនិយម និងខ្មែរនិយមក្រៅពីជាបណ្ឌិត ជាទស្សនៈវិទូ... លោកគ្រូជាកវីដ៏ល្បីក្នុងសម័យទំនើបយើងមិនមែនតែគុកកាមកិលេស និង ចិត្តក្រមុំទេ ដែលពីរោះប្លែកនោះ.... គ្រប់សំនេរ សម្ដី លោកគ្រូមានសូរសម្លេង និង ចង្វាក់ទាក់ទាញអ្នកផងតែម្ដងតាមនិស្ស័យសិល្បៈពីកំណើតផ្ទាល់របស់លោកគ្រូ។

សូមលោកគ្រូទទួលពាក្យកោតស្ញើចសរសើររបស់ខ្ញុំបាទចំពោះលោកគ្រូ តាមរយៈកូនសៀវភៅនេះ ដែលសម្រេចរូបរាងដោយសារការខំបណ្ដុះមួយភាគដែររបស់លោកគ្រូ។

ភ្នំពេញ ឆ្នាំ ១៩៧០ និង ១៩៧១

**ឃុន ស្រ៊ុន**

# ជីវិតដើមត្នោត

១.　គេបោះគ្រាប់ចោលតាមដីស្រែ　គ្មានថែដូចដាំចំណាំផង
　គ្មាថ្មមដូចផ្កាក្នុងរបង　អ្នកផងខ្លះកោតត្នោតព្រីក្សា។

២.　ដែលរស់ឯងឯងអង្វែងឆ្នាំ　ឈរចាំព្រំដែនដីចំការ
　គ្មានរេទន់ទេរតាមវាតា　បានត្រឹមគេថាគ្រាន់បើដែរ។

៣.　ដើមណាដុះខ្ពស់ពេញរូបរាង　គេកាប់មែកធាងបេះផ្កាផ្លែ
　គេរឹតទាំងទឹកព្រឹកល្ងាចហែរ　នៅតែត្នោតឲ្យដោយត្រេកអរ។

៤.　ដើមណាលូតខ្ពស់ហួសគេឯង　ភ្លើងផ្សែងរន្ទះរះដាច់ក
　ក្ស័យប្រាណត្រងាលកណ្តាលល្ហ　ខានផ្តល់ជាតិស្ករឲ្យអនុស្សា។

៥.　បើត្នោតអាយុថ្លៃនៅឡើយ　រន្ទះបាញ់ហើយមិនមរណា
　គេនាំគ្នាគិតនឹករអា　គេថាចង្រៃគេលែងជិត។

★ ★ ★

# សំណាក គោលគំនិតស្នេរ

សំនេរល្អៗ មានប្រយោជន៍ច្រើនដូចជាអប់រំ កែប្រែ លំហែសិក្សា រៀនបង្រៀន ឬប្រាប់បង្ហាញ ឬ ទុកធ្វើជាឯកសារ។ មនុស្សបង្កើតអក្សរក្នុងបំណងទាំងនេះ។ លោក គូតុងប៊ែរ (អាលីម៉ង់0 បង្កើតពុម្ភនៅសតវត្សទី១៥ ក្នុងបំណងទាំងនេះ។ ដូនតាយើងដែលរាប់រយឆ្នាំមុនខំចារលើស្លឹករឹតទាំងថ្ងៃទាំងយប់ មានបំណងដូចនេះដែរ។ ក្រៅពីនេះសំនេរល្អៗ ជាសម្បត្តិវប្បធម៌ ដ៏ឧត្តម ដែលើកកេរ្តិ៍ឈ្មោះស្រុកទេស ហើយអាចនៅរស់ជានិច្ចទោះស្រុកទេសរលាយក៏ដោយ។ ចំពោះអ្នកចូលចិត្តគិតវិញ សរសេរជួយឲ្យកើនគំនិតដូចសំនេរជួយឲ្យកើនពន្លឺ។ សម័យនេះនៅ ប្រទេសលូតលាស់លឿនៗ ការអានទំហំធំណាស់ រហូតគេអាចពោលបានពីអរិយធម៌ភ្នែក ស្រុកណាប្រើភ្នែកច្រើនជាងគេ ស្រុកណាមានកំរិតចំណេះខ្ពស់ជាងគេ នឹងអាចបានទាល់តែមានសរសេរ។ ស្រុកណាមានស្នេរល្អៗសម្បើមៗ ច្រើនស្រុកនោះនឹងមានវប្បធម៌ខ្ពស់ល្បី។ ដូនតាយើងជំនាន់មុនគ្មានសាលាថ្ម ធំៗខ្ពស់ៗ គ្មានគ្រូចេះជ្រៅចេះច្រើន ទុកជាកេរ្តិ៍ឲ្យស្រុក និងឲ្យយើងតាំងពីចារថ្មដល់ចារស្លឹករឹត តាំងពីកំណាព្យដល់ពាក្យរាយ តាំងពីរឿងតូចខ្លីដល់រឿងធំវែង។ រឿងព្រេងធនញ្ជ័យ សុភាទន្សាយ រឿងរាមកេរ្តិ៍ ទុំទាវ បណ្តាំច្បាប់ភាសិតនិងសាស្ត្រល្បែង ។ល។ ជួយឲ្យយើងមានមុខមាត់ដូចគេខ្លះដែរ តែស្តួចស្តើងណាស់ ហើយពេលនេះទៀតក៏ចំនួនសំនេរយើងមិនទាន់បំពេញក្តីត្រូវការរបស់ផ្នែកជនជាតិយើងគ្រប់នៅឡោះយ។ សេចក្តីថាគួរយើងខំសរសេរ និង ខំបណ្តុះផ្នែគសំនេរ...។

### ១. ដើម្បីទៅជាស្នេរ

ស្នេរល្បីៗស្រុកយើង ដូចជាក្រមង៉ុយ ភិក្ខុសោម ប៉ាងខាត កេង វ៉ាន់សាក់... រហូតស្នេរបទេសភាគច្រើន (វ៉ិចទ័រអុសគ្លោ - សេកស្ពារ - រូសូតាគ័រ...) មិនបានទៅរៀនសាលាប្រលោមលោក សាលាកំណាព្យសាលាល្ខោនណាទេ។ តម្លៃស្នេរក៏មិនសំខាន់ត្រង់មានសញ្ញាប័ត្រធំខ្ពស់នោះដែរ។ យើងម្នាក់ៗអាចបានទៅជាស្នេរ បានឲ្យតែះ

-មានចិត្តស្រឡាញ់ដងប៉ាកាមែន... ពិសេសខំហាត់សរសេរទាល់តែរអិល

-ខំគិតបញ្ហាមនុស្សគ្រប់យ៉ាង ពិសេសគិតអ្វីឲ្យឃើញអ្វីដែលប្លែក

-ខំមើលសៀវភៅទាំងខ្មែរទាំងបរទេស ទាំងល្អល្មម ទាំងល្អណាស់ មើលសិល្បៈកុនល្ខោន ភ្លេងចម្រៀង... មើលជីវិតស្រុកយើងស្រុកគេឲ្យឃើញច្រើន... ពិសេសជីវិតដែលមានរឿង

-ខំចេះដឹង ចេះចំណេះដឹងសព្វយ៉ាងដោយគិតផងអានផង សួរផងស្តាប់ផង កត់ផង... ពិសេសចំណេះខាងសរសេរ

-ខំរៀន... រៀនក្នុងសាលា រៀនក្នុងសង្គមមនុស្ស ក្នុងឃុំ ឬ ក្នុងគុក... ក្រៅពីនេះត្រូវសម្រេចចិត្តថា នឹងសរសេរសំនេរបែបណា ព្រោះមនុស្សម្នាក់ពូកែយ៉ាងណាក្តី មិនអាចរត់រួចទាំងអស់ជាដាច់ខាត៖

-បែបអក្សរសិល្ប៍ (កំណាព្យ ប្រលោមលោក រឿងខ្លីៗ រឿងប្រឌិត...)

-បែបសិល្បៈ (សរសេរកុន ល្ខោន ចម្រៀង ភ្លេង...)

-បែបដំណឹង (កាសែត ទស្សនាវដ្តី សំបុត្រ...)

-បែបវិទ្យា (ស្បង់ អក្សរសាស្ត្រ មនុស្សសាស្ត្រ មានចិត្តវិទ្យា ប្រវត្តវិទ្យា សង្គមវិជ្ជា ។ល។)

-បែបនយោបាយ (របៀបគ្រប់គ្រងសេដ្ឋកិច្ច)

-បែបទស្សនៈវិជ្ជា ។ល។

**២. លក្ខណៈប្រពៃនៃស្នេរ**

*ដំបូងគួរគិតថាសរសេរដើម្បីអី ដើម្បីជាតិចម្រើន ឬ ដើម្បីលុយខ្លួនឯង មេកើយឯង

ព្រោះតម្លៃស្មេរចិតត្រង់ ខ្លួនគិតយល់ឃើញយ៉ាងណាស់សរសេរយ៉ាងនោះ។ បើថ្ងៃនេះសរសេរលោក ក ស្អែកឡើងជេរលោក ក ថ្ងៃនេះបង្អាប់លោក ខ ស្អែកឡើងលើកលោក ខ នោះស្មេរនឹងស្មោះថា គ្មានគោលជំហរច្បាស់លះ។ ស្មេរនិងមានតម្លៃពេញកាលណាខ្លួនមិនមែនជាម៉ាស៊ីនរបស់ក្រុម ផ្តេសផ្តាសបោកបំភាន់ណាមួយ។ ស្មេរគួរជាខ្ញុំនៃខួរ និង គំនិតយោបល់ខ្លួនប៉ុននោះ គំនិតយោបល់ខ្លួនដើរដល់ណា សំនេរដើរដល់នោះដែរ ។ ជាឧទាហរណ៍ ៖ ស្មេរល្បីៗខ្លះ សុខចិត្តជាប់ខ្នោះ ដើម្បីរក្សាការពារគោលជំហរខ្លួន។

*គំនិតសមហេតុផលជាគ្រឹះនៃចំណោះសព្វបែបយ៉ាង ជាគ្រឹះនៃការវិនិច្ឆ័យ ឬ ដោះស្រាយរឿងរ៉ាវសព្វបែបយ៉ាង ហើយជាធាតុចាំបាច់ដើម្បីឲ្យសង្គមមនុស្សជឿនលឿន និងសុខចម្រើន។ បណ្តាជននៃស្រុកខ្សត់ខ្សោយ ឬស្រុកយឺតយ៉ាវច្រើនខ្វះគំនិតសមហេតុផលនេះឯង។ ស្មេរជាអ្នកពិនិត្យជញ្ជីងគិតពិចារណារកហេតុផលសមមិនសម និងខំប្រឆាំងអ្វីដែលមិនសមហេតុផល។ ដូចនេះគួរនាំអ្នកអានឲ្យមានគំនិតដូចខ្លួនគឺកុំឲ្យចេះតែជឿៗ ឬយល់ត្រឹមអញ្ចឹងមែនហើយៗ។ គេបង្អាប់រឿងស្រទបចេកត្រង់ស្រីកម្សត់ស្លាប់ព្រោះភោគសេដ្ឋីវាយដំនោះ ស្មេរខំបញ្ជាក់ថាមកពីកម្មពៀរជាតិមុន។ តែគេសរសេរច្បាប់បណ្តាំបិតា ដែលប្រដៅឲ្យចេះពិចារ-ណាពេលមានភ័យ (មួយសោតគេប្រាប់ជាបាពុំគាប់ ទោសដល់អាត្មាកុំបាភិតភាំង ស្លុតស្លេកកាយា ប្រាណប្រុងតរិយាស្មារតីឲ្យនឹង។ រិះរកគំនិត ភ្ញុំយោបល់គិត ទង់ទាញសន្ទឹងប្រាជ្ញាមួយកាត់ចាត់ឡើងឲ្យដឹង ចំណោះមួយនឹង ធ្វើហាក់មិនភ្លឹក)។

*ស្មេរជាអ្នកធ្វើការមួយរូបរួចទៅហើយ ៖ ការច្បាស់លះរបស់ស្មេរគឺខំសរសេរ។ បើស្មេររឿង (កំណាព្យប្រលោមលោក ល្ខោនចម្រៀង) នោះលើសត្រង់មានលួងលោម បំពេរអ្នកអានឲ្យសើរចយំភ័យអរ ស្ញើររន្ធត់ ។ល។ តាមល្បិចភ្ជក់ចិត្តដែលគេហៅថាសិល្បវិធី។ ដូចនេះគួររកល្បិចនាំអ្នកអានឲ្យធ្វើការដូចខ្លួន ពិសេសមិនគប្បីបង្ហាញរឿងណាដែលនាំឲ្យអ្នកអានទៅជាអស់សង្ឃឹមលើកម្លាំងខ្លួនឯង និងលើកម្លាំងមនុស្ស ឬទៅជារឿងចាក់ឬក៏ងប់ក្នុងជំនឿកម្មពៀរនរកប្រែតដេកទ្រាំចាំសំណាង ចាំត្រូវឆ្នោត ចាំសុំសុខពីព្រះចាំរស់ដោយសារទាន ឬ ទៅជា

រវើរវាយស្រម័យឃើញតែរឿងចំអាសនោះឡើយ។

**ជាឧទាហរណ៍៖**

-ច្បាប់បណ្ដាំបិតា ដែលទូន្មានថា (សប្បាយធ្វើស្រែ ចំការជួញប្រែ នោះមានគេរាប់ សប្បាយបានស៊ី សប្បាយបានទ្រព្យ សប្បាយនោះគាប់អាយុយឺនយូរ)។

-ច្បាប់ក្រមង៉ុយ ដែលទូន្មាន (រកស៊ីឲ្យញឹក ដេកយប់រលឹករឹតក្បិនឲ្យតឹ)។

(ភ្ញាក់ខ្លួនកាលណា កាន់ការកាលណឹង កូនអើយខំប្រឹង ទាំងប្រុសទាំងស្រី)

(ដេកយប់រៀនមមើ ស្រែកថាយើៗ អៅៗ)

(ចោរខ្មាំងខ្មោចចិត្តខ្មៅ ហៅមេខ្មៃរ៉ៃឲ្យខ្ពុក...)

-ច្បាប់ផ្សេងៗ និងបណ្ដាំក្រមង៉ុយទាំងមូលដែលទូន្មានឲ្យស្រឡាញ់ការ (សូមអានច្បាប់ទាំងនេះ)

-រឿងមហាជនកជាតក (ទសជាតក៍) ត្រង់មហាជនក ពេលជួបជជែកជាមួយទេពធីតារក្សាសមុទ្រ បាននិយាយឆ្លើយនឹងនាងជា (ដែលខ្ញុំខំហែល ៧ យប់ ៧ថ្ងៃដោយមិនឃើញកោះត្រើយ ជាជាងដេកចាំលង់ស្លាប់ដោយនៅស្ងៀមនេះ បើមិនបានផលអី ហោចណាស់ក៏បានត្រឹមជួបនាងដែរ)...

ដូចនេះស្មោះខ្លួនឯងត្រូវជាអ្នកមានសង្ឃឹម ពិសេសសង្ឃឹមលើការខំប្រឹងនិងស៊ូរបស់មនុស្ស។ អ្នកទុទិដ្ឋិនិយម ដែលប្រកាន់ថា អ្វីៗសុទ្ធតែអាក្រក់ (អាក្រក់មានចំនួន និងកម្លាំងលើសល្អ) សុទ្ធជាអ្នកអស់សង្ឃឹមយូរទៅនៅស្ងៀមធ្មឹង លែងធ្វើអ្វីទាំងអស់។

*អ្នកប្រាជ្ញនិយាយថា ជឿឬទេ រឿងរបស់វរជនម្នាក់សរសេរដោយដៃវរជននោះ ឬដោយជើងវរជននោះ ក្នុងសម័យកាលវរជននោះ រួចចាត់ចែងបោះផ្សាយដោយវរជននោះទៀត។ មែន

ការពិតតែងតែមិនងាយព្រោះការពិតវាប៉ះ ពិសេសពិតក្នុងរឿងរ៉ាវទំនាស់ ឬរឿងផ្ទាល់ខ្លួន។

ក្រៅពីសំនេរផ្នែកវិជ្ជាសុទ្ធៗ និងផ្នែកទស្សនវិជ្ជា ច្រើនចាកការពិត ច្រើនត្រូវគេកាឡៃតាមចិត្ត ឬ តាមកម្លាំងញាក់ណាមួយ ដូចជាកាសែត ទស្សនា វដ្តី-ប្រវត្តិសាស្ត្រ-សំនេរយោបាយ អត្ថបទសិល្បៈ កុនល្ខោន ចម្រៀង គំនូរ...។ ប៉ុន្តែអ្នកសិក្សា ពិសេសអ្នកជឿនលឿនតែងឲ្យតម្លៃទៅលើពិត។ ជាឧទាហរណ៍ គេរិះគន់រឿងកូលាបប៉ៃលិន ត្រង់ដែលរឿងនេះបញ្ជាក់ថាលោកហ្លួងរតនសម្បត្តិ ព្រមលើកកូនស្រីខ្លួនឲ្យចៅចិត្រជាឈ្នួល ហើយគេសរសើរក្រមង៉ុយ (ជំនាក់បារាំងត្រួត) ភិក្ខុសោម (រឿងទុំទាវ) លោកគយសារុន (បុប្ផាខ្មៅ-អាសូរដើមដូង-ឆ្នាំ១៩៦៥)៖

-ក្រមង៉ុយសរសេរថា (នគរច្ងើងប្លែក សប្បាយតែភ្នែក ក្នុងចិត្តរងកម្មកូនប្រុសបណ្តាច់កុំភ្លេចបណ្តាំ សប្បាយសូត្រថ្នាំ ត្រីម៉ាំលែងចោក... មានតែមេស្រុក វាស់បែងក្រឡា ដីមួយហិកតារ ត្រូវសែសិបចាំង។ រង្វាន់មេស្រុក ត្រូវហូតមួយទុក ដប់ជូនបារាំង ទៅដល់ប៉ុយរ៉ូ បង្ខូរដាក់ឃ្លាំង ពូជពីរកន្តាំង ក៏ជាប់ពន្ធដែរ។ គ្មានធូរគ្មានតឹង កូនអើយខំប្រឹង ជាតិឯងជាខ្មែរ ក្មេងប្រុសជំទង់ នៅក្នុងឱម៉ែ រាជការប្រើតប្រែ ថាឲ្យបង់ប្រាក់)។

-លោកគយសារុនសរសេរថា (យូរហើយដូងដុះក្នុងភូមិម្ត ដើមធាងលូតល្អមានផ្លែផ្កាស្រាប់គេផ្តាច់អាហារ គេថាគាស់ដឹកយកទៅដាំ។ ល្ងាចនេះដូងដុះក្បែរសាលា លោកអ្នករាជការខំថែទាំ តុបតែងស្រោចទឹកយ៉ាងដោគជាំ ថ្នាក់ថ្នមមុតមាំខ្លាចដូងដួល។ ព្រឹកឡើងបុណ្យសម្ពោធសាលា មនុស្សមួយខ្សៀវខ្វាមីរខ្វាញខ្វល់ ញញឹមប្រិមប្រិយ ចាំទទួល ស្រុះស្រួលចោមជុំសម្តេចឱ។ ដើម្បីដូងដាច់ឫសសប្បាយដែរ រេរាំហូរហែតាមក្បែរផ្លូវ ញញឹមស្វាគមសម្តេចឱ មើលអស់លោកត្រូវបានមេដៃ។ ព្រឹកដ៏រីករាយកន្លងទៅ ដូងនៅម្នាក់ឯងកណ្តាលថ្ងៃសូរ្យសែងក្តៅដុតគ្មានសំថៃ ដូងក្សីយចោលរូបកណ្តាលក្រុង)។

-ភិក្ខុសោមសរសេរថា (ទាំងបីស្រីប្រុសស្រុះខាងស្លាប់ ខ្មោចទុំគេកាប់ឥតជំនុំ ខ្មោចស្រីៗស្លាប់ព្រោះទុំ ទៅជុំចាត់កអន្តរធាន។ ឧកញ្ញាអរជូនកូនប្រពន្ធ ព្ទហើយស្មើរគ្រុនញ័រ។ ជើងដៃ

រន្ធត់ញ័រមាត់ហត់ហៀបក្ស័យ វិស័យមុខខ្មោច ខ្មោចខ្មៅជាំ... បង្គំទៀបទាល់ដល់មហាក្សត្រ ប្រយ័ត្នរៀបរកភស្តុទាំងឡាយ ឆ្មោតដូងស្លាចេកម្ចាស់ខ្នុរស្វាយ ខ្វល់ខ្វាយរកសព្វសត្វក្ងា ក្អែក លលកព្រាបប្រើសព្រៃ សាច់វារវសរសៃគ្រឿងសម្ល សម្លាប់យកស្នែងភ្លុកកុយថ្ម ត្រដរព្រួយប្រាណពុំមានឈប់)។

សំនេរភរបោក មិនត្រឹមធ្វើឲ្យស្នេរអត់តម្លៃប៉ុណ្ណោះទេ តែជាអាវុធបំផ្លាញសីលធម៌ ឬក្តីល្អចម្រើន មួយរយៈពេលទៀត។ រឿងជ័យមេរតដែលបង្អាប់ជ័យយ៉ាងហួសហេតុនេះ អាចឲ្យអ្នកខ្លះជឿបានថា អ្នកក្រគឺល្ងង់ដូចនេះមែនការព្រួតគ្នាជេរជនស្លូតត្រង់ណាម្នាក់ អាចនាំឲ្យអ្នកអានដែលមិនស្គាល់ជននោះ ទៅជាយល់ឬជឿបានថាជននោះខូចខុសមែន។ តែសំនេរភរបោក យូរឬឆាប់គង់គេដឹងទូទៅ។ ជាឧទាហរណ៍ ៖ បើជាន់មុនមនុស្សជឿងប់ចំពោះកម្មពៀរ នរកប្រេតដល់ជំនាន់វិទ្យាសាស្ត្រនេះ មនុស្សភ្ញាក់បន្តិចម្តងៗ។

ស្នេរខ្លះស្រឡាញ់ពិតដែរ តែមិនហ៊ាន។ ខ្លះមិនត្រឹមខ្លាចប៉ុននេះទេ តែបង្កាច់បំពានក្នុងបំណងផ្ទាល់ខ្លួនម្យ៉ាងៗ។ នេះជាកំហុសធំ ដែលផ្ទុយពីដំណើរលូត និងលឿននៃមនុស្សលោក។ ក្នុងទីមួយដែលពាក្យពិតរេងស្ងែង ស្នេរនឹងមានតម្លៃ បើហ៊ានត្រដាងពិត តាមល្បិចឬសិល្បៈដើម្បីឲ្យអ្នកផងបានដឹងឬ ភ្ញាក់។

*ក្រៅពីនេះ ស្នេរគួរជាអ្នក

-ហ៊ានស៊ូចង់ឲ្យគេបានសុខ ដោយខ្លួនឯងត្រូវចូលរួមក្នុងការប្រយុទ្ធណាមួយ ដើម្បីក្តីល្អ

-ស្រឡាញ់ភាពត្រង់ត្រឹមត្រូវ មិនឃើញតែលុយដែលអាចឲ្យឃ្លាតធម៌នឹងគឺមិនវេភ្លាវ។

-ខំរកខ្លួនឯង កុំឲ្យដូចគេសុទ្ធ (ឧ. ធនញ្ជ័យ ទុំទាវ បណ្តាំប្រមង៉ុយ រាមកេរ្តិ៍ មានលក្ខណៈថ្មីឬប្លែក)។

-សមរម្យ ៖ មិនបន្ទាបខ្លួនពេក និងមិនក្អេងក្អាង ពើង ឬមើលងាយគេ

-មានគំនិតទូលាយនិងវែងឆ្ងាយ ពិសេសមិនឃើញតែចាំឯងមួយក្រវិច។

ស្មេរខ្លះដើម្បីទាស់គ្នាឬជេរគេជេរឯង បានយកឈ្មោះផ្សេងមកដាក់។ នេះជាវិធីមួយ តែក៏ជាការភរខ្លួនមួយដែរ។

*សង្កេត ៖ រវាងស្មេរ និង ស្មេរគេតែងឃើញ

-គំនិតផ្ទុយគ្នា ម្នាក់យល់យ៉ាងនេះ ម្នាក់យល់យ៉ាងនោះ ជួនដល់ឈ្លោះគ្នាប្រកាន់ត្រូវរៀងខ្លួន (ឧ. រ៉ុលទែរនិងរូស្សូ)

-ការចម្លងគ្នា (អ្នកក្រោយចម្លងអ្នកមុន ឃើញដូចអ្នកមុន យកលំនាំអ្នកមុន ឬយកអ្នកមុនជាគ្រូ)

-ការរិះគន់គ្នា (ប្រទេសខ្លះ មានស្មេរដែលចាំតែធ្វើសំនេររិះគន់)

-ការរួបរួមគ្នា ជួយគ្នាគ្រប់ផ្នែក (បង្កើតក្រុមឬសមាគមស្មេរ)។

តែគេមិនដែលកែ ឬសរសេរថែមលើសំនេររបស់ស្មេរម្នាក់ទៀតដែលមានរួចមកហើយទេ។ ជាឧទាហរណ៍ ភិក្ខុសោម បញ្ចប់ឲ្យទុំឲ្យនិងទាវស្លាប់។ បើយើងអាណិតគូទាំងពីរពេករហូតសរសេររឿងទុំទាវមួយទៀតដោយឲ្យរស់វិញ នោះយើងឈ្មោះថា ខុស ពិសេសយើងមិនគោរពវិញ្ញាណស្មេរដែលចែកឋានទៅ...។

★ ★ ★

# សិទ្ធស្មេរ

ស្មេរមានសិទ្ធិហាម ចោទប្រកាន់ និងប្តឹងតាមច្បាប់ចំពោះជនណាដែលចម្លងផ្សាយ ឬប្រែសំនេរខ្លួនដោយគ្មានអនុញ្ញាត។ តែសិទ្ធិធំបិតត្រង់ស្មេរអាច ផ្សាយសំនេរដែលខ្លួនពេញចិត្ត និងយល់ថាល្អចម្រើន នេះទៅវិញ ។ សេចក្តីថាបើគេហាម មិនឲ្យស្មេរម្នាក់ផ្សាយអ្វីមួយ ដែលចែងពីគំនិតលឿន គំនិតស្អាត គំនិតស្នេហ៍ជាតិ ។ល។ នោះគេឈ្មោះថារំលោភសិទ្ធិស្មេរ។ តែការរឹបអូសៀវភៅចំអាស សៀវភៅថយក្រោយ សៀវភៅភរបោកពុំមែនជាការបំពានសិទ្ធិស្មេរជាដាច់ខាត។ ជាឧទាហរណ៍ ៖ អាជ្ញាធារបារាំងជាន់មុនដែលហាមមិនឲ្យមូលីយែរ ឬ ឌីដឺរ៉ូ ឬ រូសូ ផ្សាយសំនេរខ្លួន ត្រូវមានឈ្មោះថាបំបាត់សិទ្ធិស្មេរ... បើយកស្មេរដាក់គុកទៀត នោះរឹតតែឈ្មោះថាបំពានសិទ្ធិស្មេរយ៉ាងខ្លាំង និង យ៉ាងស្តែងទៅទៀត។

សមាគមស្មេរដែលធ្លាប់ ឬ នឹងធ្លាប់ជួយផ្តុងផ្តើម ជួយណែនាំ ឬជួយបោះផ្សាយសំនេររបស់ស្មេរនោះ នឹងទៅជាមានប្រយោជន៍មែនទែន កាលណាបានបម្រើសិទ្ធិស្មេរពេញលេញដូចពោលខាងលើ។

★ ★ ★

# សង្កេតចំពោះលក្ខណៈប្រពៃណីសំនេរ

កូនចំរោស ឬ សំនេរចំអាល ដែលគេហាមក្មេងអាយុតិចជាង ១៨ឆ្នាំ យើងអ្នកអាយុម្តេច្លាយ មើលទៅ អានទៅ ក៏នៅតែភ្លើតភ្លើន វក់ផ្គាស់ដែរ។ គំនិតខ្លះយល់ថា សំនេរល្អ ឬ មិនល្អ អាស្រ័យអ្នកអាន អានហើយគ្រាប់តាមទាំងអស់ ឬ មួយគិតពិចារណា ឃើញត្រូវក៏ធ្វើតាម ឃើញខុសក៏ទាត់ចោល។ យល់បែបនេះ ពិបាកយកជាការ។ តាមពិតសំនេរល្អ មានលក្ខណៈល្អផ្ទាល់របស់ខ្លួន ពិសេសជម្រៅ ៖ អ្នកអានណា មានកម្រិតខួរទាបចាប់សេចក្តីបានតិច ឃើញល្អត្រឹមប៉ុននោះ ឃើញល្អត្រឹមប៉ុននេះ អ្នកអានណាមានសមត្ថភាព ឬចំណេះខ្ពស់ឃើញល្អ

ច្រើនដល់ប៉ុននោះ... គឺថាទោះអ្នកអានប្រភេទណាក៏ឃើញល្អដែរ ហើយបើមិនឃើញល្អ គឺមិនឃើញអាក្រក់ដែរ។ ជាឧទាហរណ៍ ពាក្យថា (ក្របីស៊ីស្រូវបងមិនសូវហ៊ានដេញ ក្របីដើរចេញបងដេញឲ្យស្រីមើល) អ្នកធម្មតាឃើញត្រឹម ក្របីមែនទែន អ្នកចេះដឹង ឃើញហួសនេះ ហើយអ្នកទាំងពីរទទួលថា ពាក្យនេះត្រូវល្អ និងមានតម្លៃ។

★ ★ ★

## សំណាកអំពីរបៀបសរសេរ

ជម្រៅជាសាច់ ឬជាតិជៅ ដែលនាំឲ្យអត្ថបទ មានលក្ខណៈល្អឬ មិនល្អ ទៅមុខ ឬទៅក្រោយ ប្លែកថ្មី ឬ ក៏ដូចគេដូចឯង។ រាងជាសំបកតែជាសំបកដែលមិនអាច របក ឬ របេះពីសាច់។ គំនិតជដែល បញ្ហា ដែលជួនកាលពីរោះ ឬមិនពីរោះ ដោយសាងរាង ផ្សាយចេញរួច ឬមិនរួចដោយសាររាងសាបសូន្យ ឬមិនសាបសូន្យ ដោយសាររាង។

ស្មេរខ្លះ ប៉ិនគិត តែមិនសូវប៉ិនសរសេរ ខ្លះទៀតប៉ិនសរសេរ តែមិនសូវមានគំនិត។ អ្នកទាំងពីរសុទ្ធតែមិនទាន់គ្រប់ បើបូកចូលគ្នាកើតនោះប្រហែលប្រសើរណាស់។ តែអ្នកទី១ ចាត់ថាគ្រាន់បើ ឬ សំណាងជាងដោយសព្វថ្ងៃមានសាលាបង្រៀនសិល្បៈសរសេរ (ដូចសម័យបុរាណមានសាលារៀនសិល្បៈនិយាយដែរ)។

ភាពមិនបានទាំងគ្រប់នេះ ជាភាពធម្មតាដែលមានទូទៅក្នុងធម្មជាតិ ដូចអ្នកខ្លះប៉ិនសរសេរ តែមិនចេះនិយាយឬប៉ិននិយាយតែសរសេរមិនកើតយ៉ាងនោះដែរ។ យ៉ាងនេះទើបជនណាបានទាំងសម្បុក ច្រើនមានតម្លៃឬរស់យូរអង្វែង។

វិធីសរសេរផ្សេងៗ មានបច្ចេកទេសវិធីជាដើម (វិធីតែងតាមប្រភេទសំនេរដូចជាតែងសិល្ប៍អត្ថបទ តែងពាក្យចួន តែងអត្ថបទកាសែត សំបុត្រ។ល។) អ្នកសិក្សាប្រហែលឃើញអស់ហើយ ក្នុងការសិក្សាអក្សរសាស្ត្រ។ យើងគ្រាន់តែជួយ បន្ថែមសេចក្តីខ្លះដែលប្រហែលអ្នកអាន

ខ្លះ មិនទាន់សូវចាប់អារម្មណ៍ ៖

១- ពាក្យ ៖ ពាក្យជាគ្រឿង ឬ ខ្មៅ ដែលមានមុខងារសំខាន់ជាងគេក្នុងសំនេរ។ ស្នេរធំៗខ្លះ គិតហើយគិតទៀតរួចថ្លឹង និងផ្ទត់ផ្ទង់យ៉ាងច្រើនសារ ទំរាំដាច់ចិត្តប្រើពាក្យនេះ ឬ ប្រើពាក្យនោះ។ គេចាប់អារម្មណ៍តាំងពីសម្លេង តាំងពីចំនួនព្យាង្គ រហូតដល់ ន័យសេចក្តី ទំងន់និងសម្រស់របស់ពាក្យ។ ស្នេរល្អៗសុទ្ធតែពូកែរើសពាក្យប្រើ។ ជាឧទាហរណ៍ ៖ ក្នុងឃ្លាថា (ព្យុះសង្ឃរាមួយនៅក្នុងខួរ) របស់លោកអ៊ុយគ្គោ យើងអាចឃើញកម្លាំងនៃពាក្យ ព្យុះសង្ឃរា ពាក្យមួយ និង ពាក្យ នៅក្នុងខួរ... ដែលចងក្រងគ្នាបានរូបារម្មណ៍យ៉ាងពេញល្អ។

-ពាក្យ (ការពិតចំពុះទុងជាមធ្យោបាយគ្រប់គ្រាន់ សម្រាប់ដកហូតព្រលឹងរាប់ពាន់ពីពិភពលោកប្រសើរជាច់គេនេះ) (វ៉ុលទែរ រឿងកង់ឌីត)។

-ពាក្យ (ក្របីស៊ីស្រូវបងមិនសូវហ៊ានដេញ ក្របីដើរចេញបងដេញឲ្យស្រីមើល)។

-ពាក្យ (បានតែសេរី ពោះនៅឃ្លាន គឺគ្មានសេរីទេពាលពៅ តែឃ្លានមនុស្សលោកឃ្លានជ្រាលជ្រៅ ឃ្លានបាយ ផ្ទះនៅ ឃ្លានសេរី)។

២- សេចក្តីផ្តើម ៖ មិនមែនគ្រាន់តែសម្រាប់បង្ហាញដំណើររឿងថា តទៅទៀតអត្ថបទនិយាយពីអ្វីប៉ុណ្ណោះទេ តែមាននាទីសំខាន់ណាស់សម្រាប់ទាក់ទាញអារម្មណ៍អ្នកអានឲ្យភ្ញាក់ឲ្យឆ្ងល់ ឲ្យជក់ចិត្ត ឲ្យដកភ្នែកពីសំនេរពុំរួច។ យ៉ាងនេះទើបស្នេរខំផ្តើម តាំងពីពាក្យសម្រាប់ចំណងជើងឡើងទៅ...។ យ៉ាងនេះទៀតទើបគ្រូតែងតែពន្យល់យើងថា សំអិតសំអាងសេចក្តីផ្តើមឲ្យមែនទែន។ ឡាប្រ៊ុយយែរ ស្នេរបារាំងនៅសតវត្សទី១៧ មានលក្ខណៈដូចជនម្នាក់ៗឈរក្បែរចិញ្ចើមថ្នល់ចាំបក់ដៃហៅអ្នកដំណើរ ឲ្យងាកមើលសំនេររបស់ខ្លួន... មើលឃើញភ្លាមជាប់ចិត្ត ចង់ដឹងចង់ស្គាល់ពីដើមដល់ចប់... ហើយនឹងដើរចេញរួច លុះណាបានផ្ចិតសំនេរនេះជាប់ខ្លួន។ លោកគយ សារុន ស្នេរសៀវភៅ (បុប្ផាខ្មៅ) បានផ្តើមដោយបង្ហាញអត្ថបទ (ឱ! ដើមអំពិលទឹក) ជាអត្ថបទពិសេសមួយដែលមានប្រវែងត្រឹម ៧ល្បះប៉ុណ្ណោះ តែស្នេរប្រើពេលជាង

មួយឆ្នាំ ទំរាំសម្រេច (សូមអានអត្ថបទនេះ)។

៣- សេចក្ដីចប់ ក៏ដូចនេះដែរ គឺត្រូវចប់ឲ្យ (ឆ្ងាញ់) ឲ្យអ្នកអានមិនអស់អាល័យ ឬ មិនបានប៉ាន់ដល់ថាដល់ម្លឹង។ ការចេះបញ្ចប់ល្អ ជួយសណ្ដោងសំនេរទាំងមូលឲ្យកើនតម្លៃនិងសំនេរ។

៤- សំនេរ ត្រូវមានរបៀប មានឯកភាព ហើយទាក់ទងគ្នានៅជុំវិញអ្វីមួយ(សូមមើលតែងសេចក្ដីរបស់លោក កេងវ៉ាន់សាក)។ ក្រៅពីនេះត្រូវមានលក្ខណៈខ្លឹម ឬ តាន់។ គេសង្កេតឃើញថា សំនេររបស់បេក្ខជនផ្ញើយមកវិញរឿងរាមកេរ្តិ៍ខ្មែរ មានលក្ខណៈទាំងនេះគ្រប់គ្រាន់...។

៥- សម្ដីស្ដីរួចហើរបាត់ទៅ បើគេមិនថតទុក... ចំណែកសំនេរនៅជិតដាមជាប់ស្នាមហ្មួតជួនអាចរស់រយពាន់ឆ្នាំ ត្រចៀកអាចស្ដាប់មិនទាន់ ឬ ក៏មិនចាប់ភ្លឹក។ ផ្ទុយមកវិញភ្នែកអ្នកអានអាចមើល ហើយមើលទៀត ទាល់តែឃើញកំហុស ឬភាពឆ្គងផ្សេងៗ។ យ៉ាងនេះទៀតទើបសំនេរខ្លះយើងអានម្ដងពីរដង ឬច្រើនដងក្ដី ក៏នៅតែយល់មិនអស់ ហើយស្នេរធំៗភាគច្រើនច្រើននិយាយមិនសូវលឿន។

៦- ក្រៅពីរាប់រៀបមកថ្វីដៃស្នេរម្នាក់ៗ ចិតត្រង់សរសេរយ៉ាងណាឲ្យសំនេរខ្លួនមានលក្ខណៈជាគំរូមួយបែបខ្លួនផ្ទាល់។ ពេលនោះសំនេរ និង រស់មិនសាបសូន្យ។ ឧទាហរណ៍ ៖

-រឿងធនញ្ជ័យ (ហៃអើៗអាជ័យធ្លាក់ទឹក -សេះកូនអុក -មានឈ្មោលអត់ពង -ស៊ីត្រីប្រាកំចោលស្រេកី ។ល។) និងរឿងព្រេងទៀត មានសុភាទន្សាយ អាខ្វាកល់អាខ្វិន ។ល។

-រឿងរាមកេរ្តិ៍ (ព្រះរាមចូលកោដ្ឋ - កុម្ភកាណីនិងពាលីស៊ូស្លាប់)

-ទុំទាវ (ឃ្លាល្អៗដែលគួរតាំមានច្រើនណាស់)

-បណ្ដាំក្រមង៉ុយ -បុប្ផាខ្មៅ -គុកកាមកិលេស -ច្បាប់ផ្សេងៗ ។ល។

**សង្កេត ៖**

១. ធម្មតាស្មេរធំៗនីមួយៗមានលក្ខណៈ និង វិធីសាស្រ្តរបស់ខ្លួនផ្ទាល់ប្លែកពីគេអ្នកសិក្សាអាចរកម្ចាស់សំនេរឃើញក្នុងករណីខ្លះ ដែលស្មេរមិនប្រាប់ឈ្មោះថាចំៗ។

២. ជួនកាលមិនត្រឹមសំនេរទេ ដែលគេមិនងាយយល់ ស្មេរក៏គេមិនងាយយល់ដែរ ស្មេរខ្លះត្រូវកប់បាំងរាល់រយពាន់ឆ្នាំ ខ្លះត្រូវរងទោស ជាប់គុកច្រវាក់ ឬបាត់បង់ជីវិត ខ្លះត្រូវគេមើលងាយសព្វបែបយ៉ាង។

តែតម្លៃស្មេរ ពិសេសតម្លៃនៃការខំតខំសរសេរចិតត្រង់បានជួយលើកដំកើងវប្បធម៌ ស្រុកទេសខ្លួននេះឯង។ សព្វថ្ងៃដោយយើងមិនទាន់សំបូរសំនេរល្អៗជាភាសាជាតិ មានអ្នកសិក្សាឬអ្នកអានខ្លះបែកគំនិតថា ប្រសិនបើខ្លួនគេកើតជាកូនបារាំង កូនអង់គ្លេស កូនជប៉ុនវិញ មិនដឹងសប្បាយ ឬចេះយ៉ាងណាទេ...។

★ ★ ★

# ជីដូនមួយខ្ញុំ

ខ្ញុំមានជីដូនមួយម្នាក់ឈ្មោះ រតនា ៖ ឪពុកគេជាប្អូនឪពុកខ្ញុំបង្កើត។ យើងរៀនជាមួយគ្នាតាំងពីក្មេង។ គេខ្សោយជាងខ្ញុំ។ កាលប្រឡងស្ទីវកាយើងអង្គុយជាប់គ្នា ដល់ប្រឡងថ្នាក់ទី៦ យើងអង្គុយជាប់គ្នាទៀត យើងបានជាប់ចូលរៀនអនុវិទ្យាល័យជាមួយគ្នា ដល់ថ្នាក់ទី៥ រៀននៅខេត្តបានមួយខែ មាខ្ញុំបានផ្លាស់មកភ្នំពេញ។ គាត់យកខ្ញុំមកជាមួយគ្រាន់បានជាគ្នានឹងគេ។ ដល់ភ្នំពេញគាត់ស្គាល់គេឯងច្រើនឡើងៗ ធនធានគាត់ធូរឡើងៗ រតនាដើរលេងក៏ច្រើនឡើងៗដែរ។ គេខ្សោយទៅៗទីបំផុតគេប្រឡងឌីប្លូមធ្លាក់។ មាខ្ញុំតូចចិត្តមិនតិច។ សំណាងល្អ ដល់ប្រឡងប្រិវេ គេនៅបន្ទប់ជាមួយខ្ញុំ ហើយតាមលេខតុត្រូវអង្គុយក្បែរខ្ញុំទៀត។ ដោយមាខ្ញុំពឹងផងដោយគេពឹងផង ដោយខ្ញុំជាប់ឌីប្លូមហើយផង ដោយខ្ញុំអាណិតគេផង និងដោយខ្ញុំត្រង់នឹងគេផង ខ្ញុំក៏ដាក់ប្រឡងឲ្យគេ គឺកិច្ចការគេត្រូវដាក់ឈ្មោះខ្ញុំ ដាក់លេខតុខ្ញុំ ឯកិច្ចការខ្ញុំត្រូវដាក់ឈ្មោះគេដាក់លេខតុគេ គេជាប់ដូចចង់។ គេអរណាស់ ខ្ញុំក៏អរដែរ ហើយមាខ្ញុំក៏អរមិនតិច។ គាត់បញ្ជូនគេទៅរៀននៅស្រុកបារាំងភ្លាម។ បីឆ្នាំក្រោយមកគេត្រឡប់មកវិញ ដោយស្ពាយបាក់ឌុបមកផង។ គេបានចូលធ្វើការក្នុងកន្លែងមួយយ៉ាងគ្រាន់បើ គេមានកូនចៅហៅដែកគន់ ទាំងក្មេងល្អក ហោចណាស់ក៏ត្រឹមលោកៗដែរ។ ខ្ញុំតាមពាក្យណែនាំរបស់គ្រូផង របស់ម៉ែឪផងរបស់ញាតិមិត្តខ្លះផង នឹងតាមចំណង់ចំណូលចិត្តខ្លួនឯងផង បានចូលធ្វើគ្រូតាំងពីជាប់បាក់អងម្ល៉េះ។ ក្នុងឋានៈជាសាស្ត្រចារ្យខ្ញុំត្រូវចេញទៅធ្វើការនៅខេត្ត។ តែយើងតែងជួបគ្នារាល់វ៉ាកង។ មកទល់ពេលនេះ តែនាធ្វើការបានបីឆ្នាំ គេនៅកម្លោះទេ ខ្ញុំក៏ដែរ តែគេជិតការប្រពន្ធហើយ ការជមួយកូនលោក ... ម្នាក់ ឮថាឪពុកក្មេកប្រុងចែកនេះនោះឲ្យគេច្រើនណាស់។ គេសំណាងមែន! រួចមិនទាន់ការផងគេសន្សំបានឡាន ៤០៤ មួយជាស្រេច។ គេមានម៉ាក់ច្រើនណាស់សុទ្ធតែប៊ិនដើរលេង ប៊ិនចាយ និងប៊ិនឆើតឆើតដូចគេ។ គេឧស្សាហ៍ហៅខ្ញុំដើរដែរ ដើរដោយមិនចាំបាច់ឲ្យខ្ញុំចេញលុយមួយរៀល។ តែដោយនិស្ស័យខ្ញុំផ្សេងពីគេខ្ញុំចេះតែមិនសូវបានទៅ ៖ ហៅពីរបីដង ខ្ញុំទៅម្តងខ្លាចគេអន់ចិត្ត។ ល្ងាចថ្ងៃសៅរ៍មួយ គេបបួលខ្ញុំថាដើរទៅនេះទៅ

នោះឲ្យណាណាណីម្តងជាមួយពួកម៉ាកគេមុននឹងគេការប្រពន្ធ។ ខ្ញុំព្រមអ៊ី។ ដំបូងយើងនាំគ្នាផ្ញើលផ្សារ។ រួចយើងមើល កុន។ ចេញផឹកស៊ី។ ហើយទីបំផុត រតនា និង មិត្តគេពីរនាក់ទៀតដើរទៅរក (...) បានពីរបីសុទ្ធតែមហាស្រស់។ ស៊ិយអី ពេលនោះខ្ញុំស្រាប់តែឈឺពោះទ្រាំមិនបាន។ ដោយខ្ញុំអង្វរពេកគេក៏យកខ្ញុំមកផ្ទះ ហើយគេបង្ហួសទៅ... ទៅឯ... ដោយបញ្ជាក់ហើយបញ្ជាក់ទៀតថាថ្ងៃស្អែកចាំនាំខ្ញុំទៅ មិនឲ្យខាន។ យប់ពិសេសនោះ ប្រហែលម៉ោងបួន មានគេមកតាមមាខ្ញុំឲ្យទៅពេទ្យធំ។

អស្ចារ្យណាស់... ព្រះអើយ! រតនាស្លាប់ទៅហើយ! មួយឡាន ៤០៤ ស្លាប់ទាំងអស់ សល់តែនាងស្រស់ម្នាក់ដែលអង្គុយកណ្តាលគេ នៅខាងក្រោយហើយដែលត្រូវរបួសធ្ងន់គួរសម។

តាមសម្តីនាងនោះ ប្រុសៗទាំងបីផឹកសម្បើមណាស់ រហួតបើកឡានទាំងស្រវឹងនិងទាំងស្រវាំងពីជ្រោយអំពិលមកផ្ទះវិញ។ ដល់ផ្លូវកាច់កោងក្បែរបឹងស្នោរឡានក៏ជ្រុលចង្កូត បុកដើមអំពិលទឹកក្បែរចិញ្ចើមថ្នល់ ហើយធ្លាក់ក្នុងបឹងទៅ។ អ្នកស្រុកក្បែរនោះនាំគ្នាមកមើល និងជួយចាត់ចែងដឹកមកពេទ្យដែរ តែហួសទៅហើយ។ គេថារតនា និងមិត្តម្នាក់ដែលជិះខាងមុខព្រមទាំងនាងស្រស់ម្នាក់ដែលជិះខាងមុខដែរបានស្លាប់នឹងកន្លែង។ ក្រោយពីគ្រោះថ្នាក់ដ៏សាហាវដ៏រន្ធត់និងដ៏អកុសលនេះមក ខ្ញុំចេះតែស្លុតនិងភាំងភាន់។ ខ្ញុំស្រម័យឃើញគេនៅនឹងមុខជានិច្ច។ រាល់ថ្ងៃខ្ញុំដេកសម្លឹងរូបថតគេ ហើយខ្ញុំចេះតែនឹកចាំសម្តីមាខ្ញុំដែលថាក្មួយអើយ វារៀនស្រុកបារាំងបីឆ្នាំ អស់ប្រហែលសាមសិបម៉ឺន នេះមិនគិតរឿងបាក់ឌុបផង។ រតនាកូនពូឆ្លាតណាស់ ធ្វើការពីរបីឆ្នាំបានឡានមួយទៅហើយបើវានៅវិញ តែពីរបីឆ្នាំទៀតប្រហែលមានផ្ទះមួយនៅដូចគេមិនខាន។

★ ★ ★

# ខ្ញុំទៅដែលត្នោ

ម៉ែឯងល្ងង់ណាស់ មីងក៏ល្ងង់ដែរ គេកោរតាំងពីភ្នែកជញ្ជីងឡើងទៅ។ បើលក់ស្រូវអង្ករ ពោត សណ្តែក លក់ជ្រូកឲ្យគេ គេថ្លឹងបង្ខាតទំងន់តាមចិត្តបើទិញត្រីសាច់ ស្ករស អំបិល ខ្ទឹងគេវិញ គេថ្លឹង ៨ខាំ ថា១គីឡូក៏គ្មានដឹងអីដែរជឿឡើងជឿអ្នកតា ជឿស្រោចទឹក ជឿថាងាប់ហើយកើតវិញ ជឿនរកប្រេតត្រង់ខ្លួនឯងម្ទៀរ ដោយសារគេធ្វើស្រែកលើខ្នងលើគោក ឬគេជិះគេជាន់គេកេងគេកោរ ទៅជាថាខ្លួនមានកម្មជាតិមុនសាងអាក្រក់ បានជាជាតិនេះក្រ... រួចហើយប្រាប់ថាពេទ្យ ថាស្បង់ឆុតឆាប់ពូកែ ពិតជាក់ស្តែង ឬថាអាមេរិកទៅដល់ខែមួយសាកលលោកដឹកឮ បែរជាថាគេភរទៅវិញ... ល្ងង់យ៉ាងនេះអស់ផ្លូវកែហើយ... កុំគ្រាន់បើពេកអាសំអុយ អញឲ្យឯងរៀនឲ្យចេះឲ្យដឹង ឲ្យបានធ្វើថីថុង មិនមែនឲ្យមកដៀលប្រដៅទេ បើល្ងង់មិនមែនចិញ្ចឹមក្បាលឯងរស់បានប៉ុណ្ណឹងទេ ឲ្យរៀនយូរទៅឆ្កួតឡើងៗលែងជឿបុណ្យបាបអីទាំងអស់ អញមិនទៅត្នោដូចឯងទេ... នរណាថ្លឹងបំបាក់ភ្នែកជញ្ជីងឲ្យវាយកទៅ ជាតិក្រោយច្បាស់ជាចុះនរកហើយល្ងិតភ្នែកទៀត ហាឡើងពេទ្យៗ ម៉េចមិនមើលអុំធ្មក មើលអារអត មើលមកការច្រឹក ណឹងសុទ្ធតែពេទ្យហើយយូរៗចៀសគ្រូខ្មែរមិនរួច ចៀសស្រោចទឹកមិនរួច កុំតែបានបន់ភ្លេងសៀមថ្វាយក្បាលជ្រូកទាន់ កុំអីគេកាច់ទៅហើយ... ឯងអួតឡើង អួតពីអាមេរិកទៅដល់ខែ ដល់ពីអង្កាល់អញមិនឃើញ ឃើញតែខែដដែលមិនឃើញមនុស្សមិនឃើញយន្តហោះអី នៅលើនោះសោះ។ រួចកោតឯងចេះថា ក្រមកពីគេជិះជាន់ទៅរួច នរណាជិះជាន់ឯង នរណាគេកោរឯង ស្រូវគេទិញឲ្យថ្លៃតាមហ៊ាន តាមហាំឆេង ឯងព្រមលក់ មិនព្រមហីទៅ សហករណ៍ឲ្យថោកជាងគេមួយហាបដល់ម្ភៃរៀលផង... ឯងចងការគេ ១០០ គេយកចុង ១០៖ ៩៖ ៨៖ មួយខែអញ្ចឹងហើយឯងហ៊ាន ឯងមិនហ៊ាន ហី គេមានអង្វរឯណា បើគេដឹងថា ជើងស្អុយ ជើងស្អុយ រកព្រឹកខ្វះល្ងាចទៀតនោះទៅរកគេ គេមិននមើលមុខ មិនយកត្រចៀកស្តាប់ មិនចង់ឲ្យជាន់ជណ្តើរផ្ទះផងអីវ៉ាន់គេលក់គេតម្លើងថ្លៃអញ្ចឹងហើយព្រោះគេចង់ចំណេញ ចង់មានបានឯងហ៊ានទិញ ហ៊ានឯងមិនហ៊ាន ហី មាននរណាបង្ខំឯង... និយាយមកតែរបៀបឆ្កួតថាងាប់ទៅមិនកើតទៀត ចុះកូន

បងសុខ កូនអាចារ្យសៅ កូនមីខ្យាន ដឹងជាតិច្បាស់ចែស ណឹងយ៉ាងម៉េច អញមិនទៅភ្លើទេ អញដឹងអស់ហើយរឿងអញ្ចឹងៗ...។

និយាយដូចម៉ែឯងស្រេចហើយ ខ្ញុំមិនចង់វែកញែក ព្រោះរឿងនេះវែងឆ្ងាយពេក... និយាយឲ្យខ្លីទៅ មនុស្សល្ងង់មិនព្រមដឹង មិនព្រមទទួលថាល្ងង់ទេ បើគេប្រាប់ថាល្ងង់ ប៉ុខឹង ដាច់ក្បាលដាច់កន្ទុយឥឡូវណឹងហើយ...

-មកល្ងង់ៗដាក់អញ មកដៀលអញ ដែលបានអីជាដុំកំភួនឲ្យអញក្រេងរាល់ខែ ដឹកអង្ករពីស្រែយកទៅស៊ីទេឬ... លុយឲ្យអញមួយខែបួនប្រាំរយ ឬមួយពាន់ណឹងយកទៅវិញទៅ អញមិនឃ្លានទេ ចាយរបស់ឯងមិនឆ្ងាញ់ទេ កុំតែមកដៀលអញថា ល្ងង់ៗបានហើយ... ឯងនេះងាប់ទៅចុះនរកហើយ បើនៅតែឆ្គួតអញ្ចឹង...

-ចេះតែពូកែហើយ អញ្ចឹងបានជាស្រូវ គុម្ពសង្វិតៗស្កកសឹងរាល់ឆ្នាំ ហើយមួយគួរៗមិនបានដប់ម្ភៃគ្រាប់ផង រួចធ្វើស្រែមួយឆ្នាំ ស៊ីមិនចង់ដល់ឆ្នាំក្រោយវិញផង...

-ល្មមៗបានហើយ កុំឌឺដងបញ្ឈឺអញពេក អានាម៉ឺន... កុំថាឯងមានកូនមួយ កូនដប់ក៏អញមិនខ្លាចដែរ... គិតអត់មិនបានទាំងនៅនឹងមុខប្រពន្ធកូនណា។

រឿងនេះកើតមានញឹកញាប់ណាស់ ស្ទើររាល់ពេលដែលខ្ញុំមកលេងស្រុកជួបជុំ ម៉ែឪបងប្អូន តែងជជែកលេងវាចូលដល់ភ្លាម។ ប្រពន្ធខ្ញុំទាញដៃខ្ញុំចេញយ៉ាងប្រញាប់ កាលណាឃើញម្ដាយខ្ញុំចង់តឹងបំពង់ក។ ឪខ្ញុំធ្លាប់រៀន ធ្លាប់អាន ធ្លាប់សេពគប់អ្នកចេះដឹង គាត់ជឿខ្ញុំច្រើន។ កាលណាឮរឿងនេះ គាត់សើចញើមៗ គាត់សំរួលទាំងសងខាង ដោយឃាត់ថាបានហើយៗ... ខ្ញុំចេះតែឆ្ងល់ និង ចេះតែគិត គិតហើយគិតទៀតថា ម៉េចក៏ម៉ែខ្ញុំគាត់ជឿចាក់ឫសងងល់ក្នុងជំនឿផ្ដេសផ្ដាសយ៉ាងនេះ។ ខ្ញុំដៀលគាត់ថាល្ងង់ណាស់ ភ្លើណាស់ ស្ពឹកណាស់ អញ្ចឹងបានជាក្រ។ ដល់គិតយូរៗទៅ ថ្ងៃមួយខ្ញុំយល់ ខ្ញុំភ្ញាក់ ភ្ញាក់ឲ្យព្រឺតថា ខ្ញុំទៅដែលល្ងង់ដែលអន់ មែន... ខ្ញុំបានចេះដឹង បានជឿស្បង់គិតនិច ដោយសារមានគ្រូបង្រៀនខ្ញុំ តាំងពីតូច

ដល់អាយុម្ភៃឆ្លាយ និងដោយសារខ្ញុំបានអាន បានឃើញ បានរស់ក្នុងកន្លែងចេះដឹង។ មែនដើម្បីចេះដឹងត្រូវបានគេប្រាប់ គេពន្យល់ គេបំភ្លឺ។ ចាប់ពីថ្ងៃនោះមក ខ្ញុំលែងបង្គាប់ម៉ែខ្ញុំទៀតហើយ។ ខ្ញុំពន្យល់គាត់ ពីនេះពីនោះ ឲ្យឃើញបន្តិចម្តងភ្លឺបន្តិចម្តង និង ជឿការពិតម្តង ដោយចាប់ផ្តើមពីងាយៗទៅតឹងៗ និងពីរូបី ទៅអ្វីៗ ដែលអរូបី...។

★ ★ ★

# ដុកទ័រខ្លឿន... ឬមេរៀនជីវិតមួយ

ដុកទ័រខ្លឿន ផ្នែករោគទូទៅ ចេញធ្វើការបួនប្រាំឆ្នាំហើយ។ សព្វថ្ងៃគាត់ខំរៀនឲ្យជំនាញខាងវះកាត់ ព្រោះផ្នែកនេះខ្វះអ្នកពូកែ។ គាត់មានមុខមាត់ សម្តីសំដៅ ឫកពាជាអ្នកល្អជា អ្នកឧស្សាហ៍ និង ឆាប់អាណិតគេ។ គាត់ចូលធ្វើពេទ្យ ព្រោះគ្រួសារញាតិមិត្តក្នុងភូមិ ស្រុក សុទ្ធតែប៊ិនឈឺ ឈឺម្តងៗ នាំឲ្យតឹងចិត្តខ្លាំង។

ទីមើលជម្ងឺគាត់មិនសូវឆើតទេ តែស្អាត ហើយមានសៀវភៅ និងទស្សនាវដ្ដីល្អៗជាច្រើនសម្រាប់ភ្ញៀវ មានទូទុកឯកសារ ឬព័ត៌មានស្ដីពីភ្ញៀវ និងនាឡិកាធំមួយសម្រាប់ប្រាប់ចំនួនពេលដែលគាត់មើលភ្ញៀវម្នាក់ៗ ប្រសិនបើគាត់ត្រូវការដឹង។

គាត់នឹកថាបង្រៀននៅសាលាបានមួយម៉ោង ៥០០៛។ នេះច្រើនបន្តិចផង។ ដូចនេះពិនិត្យរោគមួយម៉ោងៗ ក៏មិនត្រូវយកឈ្នួលលើសកម្រៃដែលរដ្ឋកម្រិតដែរ។ យ៉ាងនេះទើបមើលម្តងៗ អ្នកឈឺមិនសូវបង់លើសហាសិបរៀល។ ដុកទ័រខ្លឿនដូចជាយកចិត្តដាក់ចំពោះជំងឺក្មេងៗណាស់ ហើយបើអ្នកឈឺណាមិនសូវធូរធារ គាត់មើលឲ្យដោយអាណិតមេត្តាតែម្តង។ គំនិតគាត់ដូចជាគិតត្រឹមធ្វើយ៉ាងណា ឲ្យមនុស្សគ្រប់គ្នាបានជាខ្លួនប្រាណប៉ុណ្ណោះ។ គាត់សប្បាយណាស់បើមាននរណាឈឺធ្ងន់ពេលយប់ ហើយមកតាមឲ្យទៅមើលភ្លាមៗ អ្នកផងតែងនិយាយថាលោកខ្លឿនស្រួលណាស់ ចិត្តទូលាយណាស់ ព្យាបាលក៏ច្បាស់ ឲ្យទិញថ្នាំក៏ធូរៗ ធ្វើការនឿយយ៉ាងណាក៏មិនចេះរអ៊ូបែរទៅប្រពន្ធ គាត់ក៏រឹតតែស្រួលទៅទៀត...។

ជាទម្លាប់មួយ លោកខ្លឿនតែងទៅលេងស្រុកកំណើតរាល់ល្ងាចថ្ងៃសៅរ៍ ហើយនៅជួយថៃឪពុកម្តាយ និង អ្នកជិតខាង រហូតព្រឹកថ្ងៃច័ន្ទទើបបើកឡានមកធ្វើការភ្នំពេញវិញ។ ព្រឹកមួយភ្លឺច្បាស់ទៅហើយ គាត់កំពុងបញ្ជាកូនឡានលូនធម្មតា កាត់ភូមិស្រុកស្រែចំការស្រស់ញញឹម ស្រាប់ឡានដឹកអង្ករមួយមកពីមុខ បើកយ៉ាងលឿន ប្រហែលរត់គេពីគយ ឬ ប៉ូលីសដេញក៏មិនដឹងតម្រង់រកបុកគាត់តែម្តង។ ប្រពន្ធគាត់ភ័យស្ទើរលោះប្រលឹង។ ឡានទ្រុងកាន់តែជិតមែន

ទៃន។ ពេលប្រចុចនេះ គាត់កាច់ចង្កូតបើកទម្លាប់ចិញ្ចើម ចុះទៅក្នុងស្រែដោយលែងនឹកគិតអ្វីទាំងអស់។ សំណាងដែរដែលកន្លែងនោះមិនជ្រៅប៉ុន្មាន។ គ្មានគ្រោះថ្នាក់អ្វីធំដុំទេ ។ ឡានទ្រុងបើកបង្ហួសទៅជាចង់សើច។ គាត់បើកឡានឡើងលើថ្នល់វិញ ដោយមានមនុស្សទាំងនោះជួយរុញជួយលើកបន្ថែមផង។ ឡានតូចកំពិតកំប៉តដោយកន្លែង នៅរត់ទៅមុខទៅក្រោយរួចដូចដើម ប៉ុន្តែដូច ជាទាញៗចង្កូត។ គាត់បើកទ្រុយៗទាំងបង្ខំ មកដល់ភ្នំពេញក៏ប្រគល់ឲ្យជាងជួសជុល។ ជាងពិនិត្យសព្វគ្រប់ កែចុះឡើងបួនប្រាំថ្ងៃ បានធូលើសមុនបន្តិច តែជាងនិយាយប្រាប់គាត់ថា (យកល្អ សុំលោកលក់ចោលទៅទុកអាចមានគ្រោះថ្នាក់ ព្រោះវៀចចន្ទាស វៀចកង់ ដែលកែឲ្យត្រង់មិនកើត) ...។ ព្រឹកថ្ងៃច័ន្ទមួយ ពីយប់ថ្ងៃអាទិត្យមានក្មេងជិតខាងម្នាក់ក្តៅរាគយ៉ាងខ្លាំង។ គាត់ឲ្យថ្នាំដែលគាត់បានដាក់ជាប់នឹងខ្លួន តែជម្ងឺនេះតម្រូវឲ្យយកមកមើលនៅភ្នំពេញ។ យប់នោះភ្លៀងរលឹមទល់ភ្លឺ រហូតភ្លឺឡើងមានទឹកសើមលើថ្នល់កៅស៊ូបន្តិចៗ។ គាត់ដឹកក្មេងនោះ និងម្តាយវា មកជាមួយយ៉ាងប្រញាប់។ ចេញផុតផ្សារមួយ មកដល់កន្លែងដែលផ្លូវលំឆ្លងកាត់មួយកំពុងធ្វើដំណើរធម្មតា ស្រាប់ក្មេងបីនាក់រត់ដេញគ្នាឆ្លងថ្នល់ភ្លែត ធ្វើឲ្យភ្ញាក់ដូចកន្ទ្រាក់។ ដុកទ័រខ្លឿនជាន់ហ្វ្រាំងអស់ទំហឹង ព្រោះមិនដាច់ចិត្តបុកជីវិតតូចៗ ទាំងបី។ កង់កៅស៊ូអូសដ៏ឮសូរង៉ឺតយ៉ាងខ្លាំង។ កូនឡានគ្រវីគ្រវាត់ពេញផ្លូវថ្នល់ ហើយហក់ទៅបុកដើមសង្កែដែលនៅក្បែរនោះឮសូរដូចរន្ទះពេលភ្លៀងធំ។ ដុកទ័រខ្លឿនសន្លប់បាត់ស្មារតី។ ក្មេងទាំងបីរត់បាត់ស្រមោលដោយមិនដឹងភ័យនិង អរប៉ុនណា។ អ្នកផងមកមើលច្រើនឡើងៗ ហើយគេខ្នះខ្នែងដឹកគ្រូពេទ្យកម្សត់នាំទៅមន្ទីរពេទ្យ។

ខ្ញុំដែលបានដឹងឮរឿងនេះ ចេះតែគិតថា (ឱ... កាលឡានទ្រុងមិនអី មកអីជាមួយក្មេងពីរបីនាក់ដែលអត់ដឹងអីទៅវិញ...)។ ពីរ បីថ្ងៃក្រោយមក កាសែតធំមួយចុះផ្សាយថា លោកខ្លឿនបានទទួលមរណភាពកាលពីយប់ថ្ងៃ... វេលាម៉ោង៤ជិតភ្លឺ ក្នុងអាយុសាមសិបមួយឆ្នាំ នៅមន្ទីរពេទ្យខ្មែរសូវៀតដោយគ្រោះថ្នាក់ចរាចរ។ សពនេះនឹងត្រូវយកទៅបូជានៅប៉ាឆាវត្តស្ទឹងមានជ័យ នៅថ្ងៃទី... តាមចំណង់សាមីខ្លួន។ កៀនអត្ថបទផ្នែកខាងលើ ទឹកមុខលោកខ្លឿន

ញញឹម ដាក់អ្នកអានព្រិច និង ដោយមេត្តាស្មោះ។

★ ★ ★

## គ្រូចំកួត

-ម៉ែៗ ព្រឹកមិញខ្ញុំរើសបានស្វីឡមួយល្អដល់ហើយ

-នៅឯណា យកមកមើល

-ខ្ញុំឲ្យទៅលោកចាងវ៉ាង សួររកម្ចាស់ទៅហើយ

-ម៉េចមិនយកមកផ្ទះ នរណាដឹង អាកូនភ្លើ!

-គ្រូខ្ញុំថា បានបុណ្យធំណាស់ ព្រោះអ្នកបាត់ គេស្តាយណាស់ បើយើងបាត់វិញក៏ស្តាយ និង ព្រួយខ្លាំងដូចគេដែរ ហើយ...

-គ្រូអ្វែងឆ្កួត!

★ ★ ★

## ចង់ដឹងច្បាស់

-ម៉េចក៏ឯងលេងបៀរ ដឹងថាហិនឬទេ?

-ខ្ញុំចង់សាកឲ្យឃើញច្បាស់ មុននឹងជឿ

-ឯងលេងស្រី ហើយចិញ្ចឹមស្រីទៀត នាំឲ្យខូចខ្លួន និង វេទនាប្រពន្ធកូន...

-ខ្ញុំចង់សាកឲ្យដឹងច្បាស់

-ខ្ញុំចង់សាក...

-អញ្ចឹងសាកសាលីស៊ីឡាតមួយដបលមើល សាកបាញ់គេលេងមើល សាកលួចគេលមើល អាកូនសម្អុយ។

★ ★ ★

## កម្លោះខ្សែដៃ

**អ្នកគ្រូដដែលលេងជាមួយក្មួយប្រុសគាត់៖**

-ម៉េចក៏ប្រុសៗ ពាក់ខ្សែដៃ?

-បាទ ព្រោះបើពាក់ខ្សែក គេមើលមិនឃើញ

-ម៉េចក៏ឯងយល់យ៉ាងណឹង?

-បាទអាវស្រីវាលក គេមើលឃើញខ្សែក ឯអាវប្រុសអត់វាលកអ្នកឯទៀតម៉េចនឹងឃើញខ្សែកម្លោះហើយគេម៉េចនឹងដឹងថាមានខ្សែក។ ភស្តុតាងគឺប្រុសដែលពាក់ខ្សែដៃ ច្រើនពាក់អាវដៃខ្លីហើយបើអាវដៃវែង គេមូរដៃ ហើយបើមិនមួរទេ គេដាក់ខ្សែដៃក្រៅដៃអាវ ហើយរលាស់ដៃឮឆឹងៗ ហើយកម្រើកដៃចាំងភ្លឺផ្លេកៗ អើយគេឯទៀតដឹង គេឯទៀតងាកមើល ហើយល្អ ហើយពីរោះ

-អញ្ចឹងប្រុសគួរពាក់ខ្សែដៃ ឬ ទេ?

-បាទគួរ... ព្រោះល្អមើលហើយប្លែក ហើយចាប់ភ្នែក ចាប់អារម្មណ៍ហើយត្រូវច្បាប់ទៀតគឺ ប្រុសមានសិទ្ធិពាក់ដូចស្រី...

-អញ្ចឹងឯងចង់ញាក់ឬទេ?

យុវជនអេះអុញមួយសន្ទុះ ទើបតបវិញថា ទេ។

-ម៉េចក៏ទេ?

-បាទ ខ្ញុំខ្លាចគេងាកមើលខ្ញុំពេក ខ្ញុំខ្លាចដៃខ្ញុំធ្ងន់ ហើយខ្ញុំខ្លាចគេហៅខ្ញុំថាកម្លោះខ្សៃដៃ។

★ ★ ★

## ចង់ឲ្យគេស្រឡាញ់ងាយទេ

សម្លាញ់ពីរនាក់ជួបគ្នា ក្រោយពីបែកគ្នាជិតមួយឆ្នាំ។ គេស៊ីបាយបណ្ដើរជជែកគ្នាសើចលេងបណ្ដើរ...

-ម៉េចធ្វើការស្រួលឬទេឥឡូវ?

-ជាមួយចៅហ្វាយធំ អត់អីទេ តែជាមួយពួកក្រោមបង្គាប់ដូចជាពិបាកដល់ហើយ

-វាអត់កោត អត់ញញើត អត់ខ្លាច អត់ចង់ធ្វើការចូលគ្នា ហើយមើលទៅដូចមិនសូវពេញចិត្តគ្នា

-ឯងចង់ឲ្យគេខ្លាច ឬ ចង់ឲ្យគេស្រឡាញ់?

-ចង់ឲ្យស្រឡាញ់ ហើយចង់ឲ្យខ្លាចទៀត។

-ម៉េចនឹងកើត បើគេស្រឡាញ់ គេមិនខ្លាចទេ ហើយបើគេខ្លាច ច្បាស់ជាគេមិនសូវចូលចិត្ត។ តាមគ្នាយល់ ធ្វើឲ្យគេខ្លាចងាយទេ ធ្វើឲ្យគេស្រឡាញ់ទើបពិបាក។

-ឥឡូវគ្នាចង់ឲ្យគេស្រឡាញ់

-ឯងធ្វើការឲ្យម៉ត់ចត់ ឲ្យត្រង់ ឲ្យត្រឹមត្រូវ ឲ្យចេះសន្ដោស អ្នកណាល្អថាល្អ អាក្រក់ថាអាក្រក់ កុំជឿបាក្យចាក់រុក កុំគុំកូនចៅ កុំរណបរណឹបធ្វើបាបកូនចៅឯង...

-ចុះបើនៅតែមិនបានផល (ម្នាក់នេះនិយាយកាត់ដោយប្រែទឹកមុខ)

-គ្នាថាបាន

-ចុះបើមិនបាន?

-ពិតជាបាន

-អីឡូវ ឧបមាថា មិនបានចុះ

-រឿងណឹងងាយទេ នាំគ្នាលេងបៀ នាំគ្នាផឹក រួចនាំគ្នាទៅសម្ពោធទៅណា

★ ★ ★

## ឆ្អែត ចិត្ត អញ្ជូ វាផ្សេង

គេថា មនុស្ស ជោរជានិច្ចទោះខែងយ៉ាងណាក៏ដោយ... អញ្ចឹងបានជាមាខ្ញុំស្រឡាញ់ខ្ញុំ ចូលចិត្តហៅខ្ញុំដើរលេងជាមួយគាត់ ម្យ៉ាងខ្ញុំជាគ្រូថ្នាក់ទ្រើសដៃរមិនអាប់មុខគាត់ ម្យ៉ាងទៀតខ្ញុំចេះនិយាយលើកដាក់ សរសើរយ៉ាងទំនង ឲ្យគាត់រីករាយ ឬ ឲ្យគាត់ឡើងជោរ។

ល្ងាចមិញគាត់នាំប្រពន្ធកូន នឹងខ្ញុំ ទៅរកស៊ីផឹកនៅហាងធំមួយ។ ពេលឡានកំពុងលូនខ្សៀក ៖

-ខោអាវលោកពូប្លែកៗជាប់ ចេញដើរលើកណាក៏មិនដដែលៗដែរ។ ដាក់កញ្ចប់បារីលៀនពីហោប៉ាវនេះពាក់វ៉ែនតាយ៉ាងនេះ សក់ខ្មៅរលើបយ៉ាងនេះដូចអាយុម្ភៃប្លាយអញ្ចឹង(ខ្ញុំនិយាយ)។ ទាំងអស់គ្នាញញឹមព្រាយ...

-ខោអាវ វ៉ែនតា បារី ឃ្វា ថ្នាំលាបសក់ទាំងនេះឯងដើរមើលម៉ាភ្នំពេញបើមានដូច។ ទាំងអស់ណឹងសុទ្ធតែទិញមកពីបរទេស។

-ចុះអាវម៉ុងតាគ្គុយ ដែលលោកពូឲ្យខ្ញុំនេះ?

-ណឹងក៏ទិញពីបរទេស ។ អញពាក់បានពីរបីដង មានគេពាក់តាមលាន់។ អញ្ចឹងបានជាអញលែងពាក់ អញឲ្យឯង។

-ខ្ញុំឃើញខ្សៀរពីរបី ដែលលោកពូចំណាំពិសារនៅសាឡុង ល្អដល់ហើយ

-ណឹងក៏មកពីបរទេស អញដើររកមួយព្រឹកធំនៅហុងកុង ទម្រាំបាន

-រួចកូនឆ្កែពន្លួរតេកតោកក្នុងឡាននេះ ល្អដល់ហើយ

-ណឹងក៏មកពីបរទេស

-ចុះឈើគូសនេះ?

-ណឹងក៏មកពីបរទេស ។ ឈើគូសណឹងស្អាតឬទេ?

-បាទ ស្អាតល្អ ប្លែកហើយស្រួលណាស់ គូសនឹងអីក៏ឆេះដែរ។ រួចចុះ...

-ណឹងក៏មកពីបរទេសដែរ

-យីគិតទៅអស្ចារ្យមែនលោកពូ កុំថាំបាច់ដល់របស់ធំៗ សូម្បីគ្រឿងប្រដាប់កំប៉ិកកំប៉ុកក៏ល្អៗថ្លៃៗ ហើយប្លែកៗដែរ គឺសុទ្ធតែមកពីបរទេស

-ពូឯង គេស្រឡាញ់នឹងចង់រស់បែបបរទេសណា (មីងខ្ញុំឆ្លើយ)

-អញ្ចឹងចិត្តគំនិតប៉ាក៏បរទេសដែរ (កូនគាត់បន្ថែម)

-ឆ្កួត ចិត្តអញវាផ្សេង អញស្រឡាញ់ជាតិ អញខំធ្វើការបម្រើជាតិ! (ពូខ្ញុំឆ្លើយដាក់កូនគាត់)

-មែន អាទូច(ខ្ញុំបន្ថែម) ប៉ាឯងស្រឡាញ់ជាតិណាស់។

★ ★ ★

# ចង់ឲ្យខាប់ស្រួលទេ

មេវត្តមួយអង្គ ទូន្មានសិស្សលោក ជាមន្ត្រីថ្នាក់ទ្រើសម្នាក់ ដែលនៅជាមួយលោកតាំងពីតូចដល់បានចេញធ្វើការៈ

-ឯងដឹងទេ ម្តេចក៏គេប្រដៅមនុស្សខំធ្វើល្អ មុននឹងងាប់?

-កូណា (ករុណា) ដើម្បីងាប់ទៅ គេនឹកអាណិត គេស្តាយ គេស្រណោះ គេសរសើរ គេមិនងាយភ្លេចឈ្មោះ...

-ត្រូវហើយ តែតាមធ្លាប់ឃើញច្រើនមកហើយ អញយល់ផ្សេងពីឯងគេឲ្យសាងល្អ តាំងចិត្តឲ្យល្អ ព្រោះចង់ឲ្យងាយស្រួលណ៎ា ឯងមិនឮទេខ្មោចអាឆែមភូមិត្បូង ដើងកាប់ចាក់ ពេលជិតដាច់ខ្យល់ វេទនាណាស់កន្ត្រាក់ដៃ កន្ត្រាក់ជើង ក្រញេងក្រញាង ខាំមាត់ខាំធ្មេញ។ ហ៎ មីឃ្មុតខាងលិចវត្តហៀបងាប់ វៀចមាត់ក្រង៉ែវង៉ែវ ភ្នែកក្រឡោតឡោត ប្រកាច់ប្រកិន មនុស្សបីបួននាក់ចាប់មិនចង់ជាប់ ដោយសារខូចពេក ដើរមួលបង្កាច់គេ ចាក់រុកឆ្កឹះឆ្កៀលគេ ខឹងគេខឹងឯងគ្មានលោះ។ រួចអាចឹកធួក រន្ទះបាញ់ទាំងថ្ងៃសើមៗណឹង ប្រហែលឯងដឹងដែរ មកពីអីមកពីគេបន់គេជេរថា អារន្ទះបាញ់ អារន្ទះបាញ់ គ្រប់ៗមាត់ហើយចីដួងៗ អ្នកណាក៏ស្អប់ដែរ ស៊ីក៏ដោយទាល់តែលុយបានគាត់ធ្វើឲ្យដល់ពេលងាប់ផុតហើយមកវិញ ផុតហើយមកវិញ ទ្រាំមិនបានកូនចៅដាក់ក្រដាសប្រាំរយឲ្យក្តាប់ពីរបីសន្លឹក ទើបព្រមទៅ ទៅ...។

-ចុះខ្ញុំកូណាលោកគ្រូ?

-ឯង ដឹងអី! អញនិយាយនេះ និយាយទូទៅទេ...។

## ចប់ដោយសង្ខេប

សូមជូនពរឲ្យមិនអ្នកអានគ្រប់ៗរូបទទួលបាននូវជោគជ័យក្នុងជីវិតគ្រប់ពេលវេលា!